ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការអនុវត្តថវិកាឆមាសទី ១ និងការវាយតម្លៃលើការអនុវត្ត ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥

## ១- សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ (ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥) ត្រូវបានអនុវត្តអស់រយៈពេលជាង ៦ ខែ នៃឆ្នាំ ២០២៥ ដើម្បីសម្រេចបាននូវលទ្ធផលសំខាន់ៗដែលជាអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការគន្លឹះនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា ក្នុងគោលដៅឆ្លើយតបទៅនឹងសំណូមពរ, សេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជា ដែលកំពុងរស់នៅក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍ។ ដូចនេះ, អនុលោមតាមមាត្រា ៤៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងដើម្បីជាមូលដ្ឋានព័ត៌មានដែលមានបច្ចុប្បន្នភាព និងច្បាស់លាស់ សម្រាប់រាជរដ្ឋាភិបាលបន្តដឹកនាំវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំរបាយការណ៍ស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ពាក់កណ្តាលឆ្នាំនាពេលនេះ តាមការកំណត់នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយពិនិត្យ និងវាយតម្លៃអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងលទ្ធផលនៃការអនុវត្តថវិកាក្នុងឆមាសទី ១ *(ដោយផ្អែកលើតួលេខថវិកា ទាំងផ្នែកចំណូល និងផ្នែកចំណាយ គិតត្រឹមថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៥)* ព្រមទាំងការវាយតម្លៃអំពីការអនុវត្តថវិការហូតដល់ដំណាច់ឆ្នាំ ២០២៥ ដោយកំណត់នូវបញ្ហាប្រឈម និងដាក់ចេញនូវចំណាត់ការ ព្រមទាំងការស្នើឡើងនូវវិធានការផ្សេងៗ ដើម្បីធានាឱ្យការអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ទទួលបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២- ទិដ្ឋភាពសំខាន់ៗនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥

### ២.១- អាទិភាពគោលនយោបាយ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានរៀបចំ ដើម្បីទ្រទ្រង់ដល់និរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់ស្ថាប័នរដ្ឋ ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់គន្លឹះ និងជាក់ស្តែងនានា ដែលត្រូវបន្តអនុវត្តក្នុងឆ្នាំ ២០២៥ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជាទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ដើម្បីសម្រេចឱ្យបានជាអតិបរមានូវ **គោលដៅជាយុទ្ធសាស្ត្រទាំង ៥** ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ដែលជា **របៀបវារៈ**



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**គោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា** ដោយក្នុងនោះ **មនុស្ស** ត្រូវបានបន្តកំណត់ជាអាទិភាពគន្លឹះទី ១ ហើយ **ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា** ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ និងមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងទិសដៅនៃការអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលថ្មីខាងមុខ។ ទន្ទឹមនេះ, ថវិកាឆ្នាំ ២០២៥ ក៏ត្រូវបានរៀបចំឡើង ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីគោលនយោបាយ**អាទិភាពទាំង ៦** ព្រមទាំង**វិធានការគន្លឹះទាំង ៥** សម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពមួយចំនួនដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧ នៃរដ្ឋសភា។

ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្តការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ចនិងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើការអនុវត្ត**អាទិភាពចំនួន ៦** រួមមាន៖

**ទី១- ការអភិវឌ្ឍមូលធនមនុស្ស** ដោយផ្តោតលើ : ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និងការពង្រឹងភាពជាពលរដ្ឋ ក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

**ទី២- ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង** ដោយផ្តោតលើ : ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល ការកែលម្អបរិយាកាស ធុរកិច្ច និងការវិនិយោគ ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ច ពិសេសរួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក និងការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ។

**ទី៣- ការអភិវឌ្ឍវិស័យឯកជន និងការងារ** ដោយផ្តោតលើ : ការអភិវឌ្ឍទីផ្សារការងារ ការលើកស្ទួយសហគ្រាសមីក្រូធុនតូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាពថ្មី និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន ការពង្រឹងការប្រកួតប្រជែង និងការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

**ទី៤- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាប័ន្ន** ដោយផ្តោតលើ : ការធ្វើបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម និងការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។

**ទី៥- ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល** ដោយផ្តោតលើ : ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធ

នវានុវត្តន៍ឌីជីថល ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។

**ទី៦- ការបន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋ ដោយផ្តោតលើការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តការងារ ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អ ឱ្យទទួលខុសត្រូវការងារសំខាន់ៗ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់ការរបស់ក្រសួង ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈ ដែលស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្ពស់។

## ២.២- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានដាក់ចេញ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២៥ ដែលត្រូវបានវាយតម្លៃ និងព្យាករនៅពាក់កណ្តាលឆ្នាំ ២០២៤ ដោយបានកំណត់នូវសូចនាករសំខាន់ៗ ដូចខាងក្រោម៖

- កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០២៥ គឺស្ថិតក្នុងរង្វង់ ៦,៣% ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ ២០៩ ១៦៣ ប៊ីលានរៀល ឬសមមូលនឹងប្រមាណ ៥១ ៣៩៨ លានដុល្លារអាម៉េរិក ស្របពេលដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនដល់ ២ ៩២៤ ដុល្លារអាម៉េរិក;
- អតិផរណានឹងត្រូវរក្សាឱ្យស្ថិតក្នុងរង្វង់ ២,៥%;
- អត្រាប្តូរប្រាក់រៀល-ដុល្លារអាម៉េរិកនឹងត្រូវរក្សាឱ្យស្ថិតក្នុងរង្វង់ ៤ ០៦៩ រៀល ក្នុង ១ ដុល្លារអាម៉េរិក;
- ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ប្រមាណថានឹងរួមតូចក្នុងរង្វង់ -២,៦% នៃ ផ.ស.ស. ដោយសារការរំពឹងទុកពីការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏នៅបន្តមាននិន្នាការល្អ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសបញ្ជាក់ថា អាទិភាពគោលនយោបាយ, ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌថវិកា ដែលបានដាក់ចេញក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ គឺបានគិតគូរនៅពាក់កណ្តាលឆ្នាំ ២០២៤ ក្នុងពេលដែលរាជរដ្ឋាភិបាលប្រកាន់យកនូវជំហាននៃការបន្តអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន»** នៅក្នុងឆ្នាំ ២០២៥ ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ បន្ទាប់ពីបានអនុវត្តគោលនយោបាយវិត្ថារកម្មចំណាយក្នុងការអនុវត្តវិធានការអន្តរាគមន៍សង្គម សេដ្ឋកិច្ចឆ្នាំ ២០២០-២០២៣ ទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩។

## ២.៣- ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៥

ក្នុងគោលបំណងដើម្បីសម្រេចបានតាមគោលដៅខាងអាទិភាពគោលនយោបាយ និងគោលដៅខាងផ្នែកម៉ាក្រូសេដ្ឋកិច្ច, តាមការព្យាករណ៍នៅពាក់កណ្តាលឆ្នាំ ២០២៤, ដូចបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌថវិកាឆ្នាំ ២០២៥ ដូចខាងក្រោម៖

| តារាងទី ១៖ តារាងតុល្យភាពថវិការដ្ឋ (ច្បាប់ឆ្នាំ ២០២៥) | | | | | |
|---|---|---|---|---|---|
| សូចនាករ | ២០២៣ | ២០២៤ | | ២០២៥ | |
| | អនុវត្ត | ច្បាប់ | អនុវត្ត | ច្បាប់ | |
| ផសស (លានរៀល) | ១៧៧ ៣៥១ ៤៧១ | ១៩១ ៨៦២ ៣៩៩ | | ២០៩ ១៦៣ ៣៤៤ (*) | ២០៥ ៧៧៩ ៦០១ (**) |
| I. សរុបចំណូលថវិការដ្ឋ (%ផសស) | ១៩,៨៤% | ១៦,៩៤% | ១៥,០០% | ១៥,១១% | ១៥,៣៦% |
| ចំណូលក្នុងប្រទេស (%ផសស) | ១៥,៤៨% | ១៦,៥៨% | ១៤,៨៣% | ១៤,៨១% | ១៥,០៥% |
| *- ចំណូលចរន្ត (%ផសស)* | ១៥,២៤% | *១៦,៣២%* | *១៤,៥៨%* | ១៤,៥៣% | ១៤,៧៧% |
| II. ចំណាយសរុបថវិការដ្ឋ (%ផសស) | ២១,០៩% | ១៩,៣៤% | ១៧,៤៦% | ១៨,១៤% | ១៨,៤៤% |
| *- ចំណាយចរន្ត (%ផសស)* | ១៣,០០% | *១៣,៤៩%* | *១២,២៨%* | ១២,៤៦% | ១២,៦៦% |
| អតិរេកចរន្ត (%ផសស) | ២,២៥% | ២,៨៣% | ២,៣០% | ២,០៧% | ២,១១% |
| III. ឱនភាពសរុប (%ផសស) | -៥,៦១% | -២,៤០% | -២,៤៦% | -៣,០៤% | -៣,០៩% |
| IV. តម្រូវការហិរញ្ញប្បទាន | | ៣,៥០% | ៣,៣៨% | ៤,២០% | ៤,២៧% |
| - ឱនភាពសុរបនៃថវិកាថ្នាក់ជាតិ | | ២,៤០% | ២,៤៦% | ៣,០៤% | ៣,០៩% |
| - ការទូទាត់ការខ្ចី | | ១,១០% | ០,៩២% | ១,១៦% | ១,១៨% |
| V. ប្រភពហិរញ្ញប្បទាន | | ៣,៥០% | ៣,៣៨% | ៤,២០% | ៤,២៧% |
| - ហិរញ្ញប្បទានក្រៅប្រទេស | | ៣,២៧% | ៣,៤៧% | ៣,៩៦% | ៤,០២% |
| - ហិរញ្ញប្បទានក្នុងប្រទេស | | ០,២៣% | -០,០៩% | ០,២៤% | ០,២៤% |

*សេចក្តីបញ្ជាក់៖*

*- ( *) ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ដែលបានព្យាករណ៍នៅក្នុងឆ្នាំ ២០២៤ សម្រាប់ការរៀបចំច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥*

*- ( * *) ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ផ្អែកលើការវាយតម្លៃសេដ្ឋកិច្ចឡើងវិញ (ខែ កក្កដា ឆ្នាំ ២០២៥)*

តាមក្របខ័ណ្ឌនេះ ចំណូលសរុបថវិការដ្ឋឆ្នាំ ២០២៥ ត្រូវបានគ្រោងចំនួន ៣១ ៥៩៨ ប៊ីលានរៀល ស្មើនឹង ១៥,១១% នៃ ផ.ស.ស. ឬថយចំនួន ២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៤ ដោយក្នុងនោះ ចំណូលចរន្តថវិការដ្ឋ ត្រូវបានគ្រោងស្មើនឹង ១៤,៥៣% នៃ ផ.ស.ស. ឬថយចំនួន ២,៩% ធៀបនឹង ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៤។

## ៣- ការវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

### ៣.១- ការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចសកល

បច្ចុប្បន្ននេះ, ស្ថានភាពសេដ្ឋកិច្ចសកលនៅតែបន្តហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់ និងមាន ការវិវត្តយ៉ាងឆាប់រហ័ស ត្បិតទស្សនវិស័យសកលស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ ដែលរួមមាន បញ្ហាភូមិសាស្ត្រ នយោបាយកាន់តែឡើងកំដៅ និងការកើនឡើងនូវគោលនយោបាយគាំពារនិយម (Protectionism) របស់ប្រទេសមហាអំណាច ជាពិសេសសង្គ្រាមពាណិជ្ជកម្ម។ គោលនយោបាយគាំពារនិយម បាននិងកំពុង

ឈានដល់ចំណុចប្រែប្រួលមួយថ្មី ដែលកំពុងបង្កើនកំដៅបន្ថែមដល់កិច្ចសហប្រតិបត្តិការសកល និងបង្កឱ្យមានបច្ច័យអវិជ្ជមាន ដូចជាការកើននូវថ្លៃដើមទំនិញដែលស្តែងចេញពីកត្តាផ្គត់ផ្គង់ (Supply-side inflationary pressure) និងការបន្ទច់បង្អាក់ដល់ខ្សែច្រវាក់ផលិតកម្ម និងការដឹកជញ្ជូន ព្រមទាំងការប៉ះពាល់ទៅដល់លំហូរពាណិជ្ជកម្មជារួម ហើយអាចនឹងឈានដល់សង្គ្រាមពាណិជ្ជកម្ម (Trade war) ពេញទំហឹង និងសង្គ្រាមបច្ចេកវិទ្យា (Tech war) និងការបែកខ្ញែកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ការកើនយ៉ាងឆាប់រហ័សជាងការរំពឹងទុកនៃចរន្តគាំពារនិយម (Protectionist policies) និងមូលដ្ឋានសម្មតិកម្មទាំងឡាយនៃការព្យាករសេដ្ឋកិច្ចសកលបានចល័តជាប់ជានិច្ច។ ជាក់ស្តែង, ផ្អែកតាមការវាយតម្លៃរបស់ IMF ចេញផ្សាយក្នុងខែ មេសា ឆ្នាំ ២០២៥, សេដ្ឋកិច្ចសកលត្រូវបានទាញទម្លាក់មកត្រឹមអត្រាកំណើនប្រមាណ ២,៨% និង ៣,០% ក្នុងឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ ពោលគឺ ធ្លាក់ក្នុងកម្រិតប្រមាណ ០,៥ និង ០,៣ ពិន្ទុភាគរយរៀងគ្នា ពីការព្យាករក្នុងខែ មករា ឆ្នាំ ២០២៥ ដោយសារផលប៉ះពាល់ និងកម្មវិបាកនៃគោលនយោបាយគាំពារនិយម ដែលស្តែងឡើងតាមរយៈការដាក់ឱ្យអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក។ សម្រាប់សេដ្ឋកិច្ចសហរដ្ឋអាម៉េរិក, ទោះបីជាការប្រើប្រាស់ក្នុងស្រុកកាលពីឆ្នាំកន្លងទៅ មានចលនការល្អ, និន្នាការនេះបានចាប់ផ្តើមមានការថមថយ ពោលគឺ ចាប់ពីមុនការប្រកាសនូវពន្ធគយបដិការ ស្របពេលដែលពន្ធនេះ ក៏អាចនឹងជំរុញការហក់ឡើងវិញនៃសម្ពាធអតិផរណាផងដែរ។ ក្នុងន័យនេះ, ផលជះនៃការអនុវត្តពន្ធគយបដិការ នឹងកាន់តែផ្តល់កម្មវិបាកជាអវិជ្ជមានមួយកម្រិតថែមទៀតដល់ការប្រើប្រាស់ និងសកម្មភាពវិនិយោគ។ សេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ នៅបន្តមានកំណើនយឺត ដោយសារការថមថយនៃសកម្មភាពផលិតកម្ម ជាពិសេសក្នុងប្រទេសអាល្លឺម៉ង់ និងអ៊ីតាលី ស្របពេលដែលសម្ទុះនៃការប្រើប្រាស់នៅមានភាពទ្រឹងនៅឡើយ។ ចលនការកំណើននៃសេដ្ឋកិច្ចចិន ក៏រំពឹងថាមានសម្ទុះថមថយជាងការរំពឹងទុក ដោយសារកំណើនយឺតនៃការនាំចេញ និងការប្រើប្រាស់ ស្របពេលដែលស្ថានភាពវិនិយោគ ពិសេសក្នុងវិស័យអចលនទ្រព្យ នៅបន្តមានភាពទ្រឹង, ក្នុងខណៈដែលសេដ្ឋកិច្ចជារួម ក៏នឹងទទួលរងផលជះជាអវិជ្ជមានពីគោលនយោបាយគាំពារនិយម ពោលគឺការដំឡើងពន្ធគយ។

ចំពោះការវិវត្តថ្មីៗនៃការដាក់ពន្ធគយបដិការ, ក្រោយការចរចាពន្ធគយបដិការទ្វេភាគីជាមួយសហរដ្ឋ-អាម៉េរិក, ប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួនទទួលបាននូវលទ្ធផលវិជ្ជមាន ពោលគឺ ទទួលបានអត្រាពន្ធគយទាបជាងមុន ក្នុងខណៈដែលប្រទេសមួយចំនួនទៀតទទួលរងនូវអត្រាគយខ្ពស់ជាមុនទៅវិញ ដែលទាំងអស់នេះបានផ្តល់នូវសញ្ញាណកាន់តែច្បាស់ជាងមុននៃនិន្នាការផ្លាស់ប្តូរទម្រង់ និងសណ្ឋានរបស់ពាណិជ្ជកម្មសកលទាំងមូល។ ការរំពឹងទុកនៃកម្មវិបាកអវិជ្ជមានបណ្តាលមកពីភាពមិនប្រាកដប្រជានេះ បានធ្វើឱ្យមានការផ្លាស់ប្តូរ និងការបត់បែនគោលនយោបាយរបស់ប្រទេសជាដៃគូពាណិជ្ជកម្ម ទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកការទូតរបស់ប្រទេសនីមួយៗរៀងៗខ្លួន ដើម្បីបញ្ចៀសនូវកម្មវិបាកនានា ទាំងផ្ទាល់ និងប្រយោល មកលើសេដ្ឋកិច្ច និងសង្គម។ ទោះបីជាយ៉ាងនេះក្តី, ការបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ ត្រូវបានមើលឃើញថា ជាសញ្ញាវិជ្ជមានសម្រាប់ទស្សនវិស័យសេដ្ឋកិច្ចសកល, ប៉ុន្តែល្បឿននៃការបន្ធូរបន្ថយ និងព្យារសកម្ម (Calibration) វិធានការគោលនយោបាយនេះ ត្រូវបានធ្វើឡើងក្នុងជំហានយឺត និងកម្រិតទាបជាងការរំពឹងទុក ក្នុងស្មារតីប្រុងប្រយ័ត្នខ្ពស់ ត្បិតត្រូវថ្លឹងថ្លែងឱ្យបានល្អិតល្អន់ ជាពិសេសចំពោះហានិភ័យនៃការហក់ឡើងវិញនៃសម្ពាធអតិផរណា។

ជារួម, ទស្សនវិស័យសេដ្ឋកិច្ចសកល នៅបន្តហ៊ុមព័ទ្ធដោយភាពមិនប្រកដប្រជាខ្ពស់ ដោយប្រទេសនានាលើសកលលោក ត្រូវបន្តរងនូវហានិភ័យកើតចេញពីកម្មវិបាកនៃការបន្តកើនឡើងនៃចរន្តគាំពារនិយមរបស់សហរដ្ឋអាម៉េរិក ដែលអាចលេចចេញនូវសង្គ្រាមពាណិជ្ជកម្ម, សង្គ្រាមបច្ចេកវិទ្យា និងការហក់ឡើងវិញនៃថ្លៃទំនិញសកល, ព្រមទាំងភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ នៅតំបន់មជ្ឈិមបូព៌ា។ យ៉ាងណាមិញ, ចំពោះមុខនៃស្ថានភាពមិនប្រាកដប្រជាខ្ពស់ និងស្មុគស្មាញនេះ ក៏មានការលេចឡើងនូវកាលានុវត្តភាពថ្មីៗ ដូចជាលទ្ធភាពក្នុងការធ្វើសមាហរណកម្មស៊ីជម្រៅនៃពាណិជ្ជកម្មប្រទេសដទៃ ក្រៅពីសហរដ្ឋអាម៉េរិក គួបផ្សំជាមួយនឹងការបត់បែនគោលនយោបាយនានា តួយ៉ាងដូចជា ការបន្តបន្ធូរបន្ថយគោលនយោបាយនៃការរឹតបន្តឹងរូបិយវត្ថុ និងការដាក់ចេញនូវកញ្ចប់អន្តរាគមន៍របស់ប្រទេសចិន ជាដើម។

## ៣.២- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅក្នុងឆមាសទី ១ និងការវាយតម្លៃសម្រាប់ឆ្នាំ ២០២៥

មុនពេលការដាក់ពន្ធគយបដិការ និងការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ក្នុងអត្រាប្រមាណ ៦,៣% ដោយសារៈ ១). ការបន្តចលនការរឹងមាំនៃវិស័យបម្រើដល់ការនាំចេញ ពោលទាំងវិស័យកម្មន្តសាលកាត់ដេរ និងមិនមែនកាត់ដេរ, ២). វិស័យទេសចរណ៍នៅបន្តនិន្នាការកើនឡើង, និង ៣). វិស័យកសិកម្មក៏នៅបន្តរក្សាបានស្ថិរភាពនៃកំណើន។ យ៉ាងណាមិញ ក្នុងអំឡុងខែ មេសា ឆ្នាំ ២០២៥ កន្លងទៅ, ការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ បានរំពឹងថា កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៥ នឹងថមថយមកក្នុងរង្វង់ ៥,២% ដោយសារការរំពឹងទុកបច្ច័យអវិជ្ជមាននៃការអនុវត្តពន្ធគយបដិការ មកលើវិស័យបម្រើការនាំចេញ។

មកដល់ពាក់កណ្ដាលឆ្នាំនេះ, ស្ថានការណ៍បានប្រែប្រួលក្នុងទិសដៅអវិជ្ជមានជាងការរំពឹងទុក ដែលរួមមាន ការអនុវត្តពន្ធគយបដិការក្នុងអត្រា ៣៦% និងការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ដែលអាចនឹងបន្តអូសបន្លាយរហូតដល់ដំណាច់ឆ្នាំ។ ក្រោមមូលដ្ឋានសម្មតិកម្ម និងសូចនាករម៉ាក្រូសេដ្ឋកិច្ច គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥ កំណើនសេដ្ឋកិច្ចកម្ពុជា នឹងបន្តថមថយមកត្រឹមអត្រាត្រឹមតែ <u>៥,០%,</u> មួយផ្នែកដោយសារផលប៉ះពាល់នៃការបិទខ្ទប់ព្រំដែនគោក បានបង្អាក់សកម្មភាពផលិតកម្ម ដែលពឹងផ្អែកលើការដឹកជញ្ជូនវត្ថុធាតុដើម និង/ឬការនាំចេញ ព្រមទាំងលំហូរទេសចរ ជាពិសេសទេសចរអន្តរជាតិ ដែលឆ្លងកាត់ច្រកព្រំដែនគោក និងមួយផ្នែកទៀត ដោយសារការអនុវត្តពន្ធគយបដិការក្នុងអត្រា ៣៦% ដែលត្រូវបានកំណត់ថានឹងចាប់អនុវត្តពីខែ សីហា ឆ្នាំ ២០២៥ តទៅ ដែលនឹងមានផលជះជាអវិជ្ជមានដល់ការបញ្ជាទិញពីទីផ្សារសហរដ្ឋអាម៉េរិក ក្នុងត្រីមាសទី ៤ ឆ្នាំ ២០២៥។ ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក នឹងបង្អាក់កំណើនវិស័យសំខាន់ៗ ដែលគាំទ្រដល់សេដ្ឋកិច្ចកម្ពុជា ដូចជា៖ ការនាំចេញរបស់កម្ពុជា តួយ៉ាង ផលិតផលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ (គ្រឿងសង្ហារិម, សំបកកង់ និងគ្រឿងបង្គុំអេឡិចត្រូនិក) ទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ដែលការណ៍នេះ ធ្វើឱ្យនិន្នាការកំណើននៃវិស័យទាំងពីរមានការថមថយជាងការរំពឹងទុក។ បើផ្អែកតាមការវាយតម្លៃឡើងវិញនេះ, កំណើនតាមវិស័យសេដ្ឋកិច្ចសំខាន់ៗមួយចំនួនមានការប្រែប្រួល ដូចខាងក្រោម៖

(ក)-វិស័យឧស្សាហកម្ម ត្រូវបានវាយតម្លៃថានឹងមានកំណើនក្នុងរង្វង់ ៧,១% គឺថមថយជាងការរំពឹងទុកបន្តិច ដោយសារការថមថយចលនការនៃកំណើនអនុវិស័យកាត់ដេរ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ក្នុងខណៈដែលអនុវិស័យសំណង់បន្តងើបវិញ ក្នុងល្បឿនយឺត, ដូចនេះ ជារួម នៅតែជាកំណើនល្អ។ *អនុវិស័យកាត់ដេរ* ត្រូវបានប៉ាន់ស្មានថាសម្រេចនូវកំណើនក្នុងរង្វង់ ១០,១% ទាបជាងការរំពឹងទុកបន្តិច ដោយសារការរំពឹងទុកបច្ច័យអវិជ្ជមាននៃការអនុវត្តពន្ធគយបដិការ មកលើការបញ្ជាទិញ និងការនាំចេញទៅសហរដ្ឋអាម៉េរិក ជាពិសេសក្នុងត្រីមាសទី ៤ ឆ្នាំ ២០២៥ នេះ ប៉ុន្តែការនាំចេញទៅទីផ្សារផ្សេងទៀត ដូចជាសហភាពអឺរ៉ុប និងចិន ជាអាទិ៍ រំពឹងថានឹងនៅបន្តរក្សាបាននិន្នាការល្អ។ កំណើនជារួមនៃអនុវិស័យនេះ ត្រូវបានរុញច្រានដោយកំណើនល្អប្រសើរជាងការរំពឹងទុកនៃការនាំចេញផលិតផលកាត់ដេរក្នុងឆមាសទី ១ ដោយសារការខិតពន្លឿនការនាំចេញ (Frontloading) ក្នុងអំឡុងដែលពន្ធគយបដិការសហរដ្ឋអាម៉េរិក ត្រូវបានដាក់ឱ្យអនុវត្តបណ្តោះអាសន្ន (ក្នុងអត្រា ១0%) មុននឹងអត្រាផ្លូវការដាក់ឱ្យអនុវត្ត។ យ៉ាងណាមិញ, ការបញ្ជាទិញពីសហរដ្ឋអាម៉េរិកអាចនឹងថមថយខ្លាំង ជាពិសេសនៅត្រីមាសទី ៤ ឆ្នាំ ២០២៥ នេះ ដោយសារបច្ច័យនៃការអនុវត្តពន្ធគយបដិការ (ក្នុងអត្រា ៣៦%) ចាប់ពីខែ សីហា ឆ្នាំ ២០២៥ តទៅ, ខណៈដែលក្នុងត្រីមាសទី ៣ នេះនឹងពុំមានផលប៉ះពាល់ធំដុំនោះទេ ដោយហេតុថារោងចក្រមួយចំនួនទទួលបានការបញ្ជាទិញរួចរាល់ហើយ។ *អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ* ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយជាងការរំពឹងទុក ក្នុងរង្វង់ ៦,៩% ដោយសារបញ្ហាព្រំដែនរវាងថៃនិងកម្ពុជានឹងអាចបន្ទុចបង្អាក់ដល់លំហូរនាំចូលនៃវត្ថុធាតុដើម និងការរំពឹងទុកផលប៉ះពាល់នៃការអនុវត្តគោលនយោបាយពន្ធគយបដិការមកលើការនាំចេញពោលទៅសហរដ្ឋអាម៉េរិក។ យ៉ាងណាមិញ, បញ្ហាព្រំដែននឹងមិនជះឥទ្ធិពលខ្លាំងដល់ប្រវាក់ផលិតកម្មទាំងស្រុងឡើយ ដោយក្រុមហ៊ុនភាគច្រើនបានបង្វែរការដឹកជញ្ជូនវត្ថុធាតុដើមរបស់ខ្លួនទៅតាមផ្លូវទឹក និងផ្លូវអាកាសជាដើម។ គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥, ការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ដូចជា៖ គ្រឿងបង្គុំអេឡិចត្រូនិក, គ្រឿងសង្ហារិម, គ្រឿងបន្លាស់យានយន្ត, កង់, សំបកកង់រថយន្ត, និងខ្សែភ្លើង មានកំណើនល្អ ក្នុងរង្វង់ ២៤,៣%, ៣៩,៤%, ១០,១%, ៤១,៦%, ៨០,៤%, និង ១៩៤,៩% រៀងគ្នា។ ប៉ុន្តែ ការនាំចេញសូឡាក៏បន្តធ្លាក់ចុះយ៉ាងគំហុក ក្នុងរង្វង់ -៩៨,៩% ដោយសារការដំឡើងពន្ធគយក្នុងអត្រាខ្ពស់ខ្លាំងរបស់សហរដ្ឋអាម៉េរិក។ បើទោះបីផ្នែកផលិតកម្មបម្រើការនាំចេញមាននិន្នាការថមថយយ៉ាងណាក្តី, ក៏អនុវិស័យនេះត្រូវបានទ្រទ្រង់ជារួមដោយផលិតកម្មបម្រើតម្រូវការក្នុងស្រុក តួយ៉ាងដូចជានិន្នាការល្អប្រសើរនៃឧស្សាហកម្មដំឡើងរថយន្ត និងកម្មន្តសាលផ្នែកម្ហូបអាហារ និងភេសជ្ជៈ ជាដើម។ ជាក់ស្តែង បើផ្អែកលើទិន្នន័យអនុវត្តក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០២៥, អាករលើតម្លៃបន្ថែមក្នុងស្រុក (VAT domestic) មានកំណើនល្អ ក្នុងរង្វង់ ៣,៦% ដែលឆ្លុះបញ្ចាំងមិនត្រឹមតែកំណើនល្អខាងតម្រូវការក្នុងស្រុកនោះទេ ប៉ុន្តែក៏បង្ហាញពីនិន្នាការល្អខាងផលិតកម្មក្នុងស្រុកដែរ។ *អនុវិស័យសំណង់* ត្រូវបានប៉ាន់ស្មានថារក្សាកំណើនក្នុងអត្រា ២,៤% ដោយសារការមិនទាន់ងើបមកវិញនៃសំណង់ថ្លៃខ្ពស់ តួយ៉ាងដូចជាអគារពាណិជ្ជកម្ម ខណៈដែលអនុវិស័យនេះ បន្តទ្រទ្រង់ដោយសកម្មភាពសំណង់ថ្លៃមធ្យម ជាពិសេសផ្នែកលំនៅឋាន និងសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម ដូចជារោងចក្រ និងឃ្លាំង ជាដើម។ ជាក់ស្តែង, គិតត្រឹម ៦ ខែដើមឆ្នាំនេះ ការនាំចូលសម្ភារៈសំណង់ បានកើនក្នុងរង្វង់ ៤៦,២%។ ជាមួយគ្នានេះ, បរិមាណផលិតស៊ីម៉ង់ត៍ក្នុងស្រុក ដើម្បីបម្រើដល់តម្រូវការសាងសង់ក្នុងស្រុក, គិតត្រឹម

៥ ខែដើមឆ្នាំ ក៏កើនក្នុងរង្វង់ ១៦% ផងដែរ។ ស្របពេលដែលសកម្មភាពសំណង់ថ្លៃទាប ជាពិសេសផ្នែកលំនៅឋានបានងើបឡើងវិញជាសន្សឹមៗមកវិញ ក៏វិធានការទាំង ៨ ចំណុចរបស់រាជរដ្ឋាភិបាល និងវិធានការបន្ថែមក្នុងវេទិការាជរដ្ឋាភិបាលវិស័យឯកជនលើកទី ១៩ កន្លងទៅក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការ-ជួយរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ និងទ្រទ្រង់ដល់អនុវិស័យនេះជារួម។

(ខ)-វិស័យសេវាកម្ម មានកំណើនថមថយក្នុងអត្រា ៣,៨% ដោយសារកត្តាបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ដែលធ្វើឱ្យប៉ះពាល់ដល់អនុវិស័យគាំទ្រ ដូចជា បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) និងសេវាកម្មគាំទ្រផ្សេងទៀត ទន្ទឹមនឹងការថមថយក្នុងការដឹកជញ្ជូន ដែលមួយផ្នែកជាបច្ច័យពីការបិទខ្ទប់ព្រំដែនគោក និងមួយផ្នែកទៀតបណ្តាលមកពីការដាក់ពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក ដែលធ្វើឱ្យមានការថមថយក្នុងវិស័យកម្មន្តសាលជារួម។ *អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ* ត្រូវបានរំពឹងថាមានកំណើនថមថយក្នុងអត្រា ៦,៩% ដែលជាផលប៉ះពាល់នៃការបិទខ្ទប់ព្រំដែនគោក មកលើលំហូរទេសចរអន្តរជាតិជាពិសេសទេសចរដែលប្រើប្រាស់ច្រកព្រំដែនគោកកម្ពុជា-ថៃ។ យ៉ាងណាមិញ, ការបង្វែរការធ្វើដំណើរពីផ្លូវគោកមកតាមផ្លូវអាកាស (ពោលទាំងភ្ញៀវទេសចរថៃ និងភ្ញៀវទេសចរអន្តរជាតិដែលមកពីប្រទេសថៃ) នឹងបន្តចាប់ផ្តើមកើតមានក្នុងពាក់កណ្តាលចុងឆ្នាំ ២០២៥។ និន្នាការកើនឡើងនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈចំនួនជើងហោះហើរ (ចាប់ពីការបិទព្រំដែនមក)។ ជាក់ស្តែង, គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥ នេះ, ទេសចរអន្តរជាតិបានកើនដល់ប្រមាណ <u>៣,៤ លាននាក់,</u> កើនប្រមាណ <u>៦,២%</u> ស្របពេលដែលទេសចរក្នុងស្រុក ក៏បានកើនដល់ប្រមាណ <u>១៤,៦ លាននាក់</u> គឺកើនប្រមាណ <u>៥០,៣%</u>។ *អនុវិស័យលក់ដុំ-រាយ* ត្រូវបានប៉ាន់ស្មានថានឹងរក្សាបានកំណើនក្នុងអត្រា ៣,៤% ដោយសារការរំពឹងទុកផលប៉ះពាល់ដោយប្រយោលនៃគោលនយោបាយពន្ធគយបដិការ មកលើសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ជាពិសេសលើទំនិញប្រណិត និងមិនចាំបាច់ដោយសារការថមថយនៃវិស័យប្រកពចំណូល ជាពិសេស វិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ ទោះជាយ៉ាងនេះក្តី, សកម្មភាពចាយវាយជារួម នៅបន្តរក្សាបាននូវនិន្នាការវិជ្ជមាន ដែលបន្តគាំទ្រដោយការ-ប្រើប្រាស់លើទំនិញចាំបាច់ គួបផ្សំនឹងការផ្លាស់ប្តូរឥរិយាបថអាជីវកម្មពីបែបប្រពៃណី ទៅជាថ្នាលអនឡាញ ដូចជា ពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce) ស្របគ្នានឹងការបន្តធ្វើទំនើបកម្ម និងសាមញ្ញកម្មនៃប្រព័ន្ធទូទាត់ ដែលផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់ប្រតិបត្តិការទិញ-លក់។ ជាក់ស្តែង, ក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០២៥ អាករលើតម្លៃបន្ថែមក្នុងស្រុក បានកើនក្នុងអត្រាប្រមាណ ៣,៦% ដែលឆ្លុះបញ្ចាំងពីការបន្តចលនការនៃការប្រើប្រាស់ក្នុងស្រុក។ ក្រៅពីការកើនជាសន្សឹមនូវផលិតកម្ម ពិសេសលើផ្នែកម្ហូបអាហារ ដើម្បីបម្រើដល់ការប្រើប្រាស់ក្នុងស្រុក, ការនាំចូលគ្រឿងឧបភោគបរិភោគដើម្បីបំពេញបន្ថែមនូវតម្រូវការក្នុងស្រុករួមមាន៖ ប្រេងឆា, ស្ករស និងគ្រឿងបរិភោគ ជាដើម ក៏មានការកើនផងដែរ ក្នុងអត្រា ៤,៤% ស្របពេលដែលការនាំចូលទំនិញប្រើប្រាស់អេឡិចត្រូនិក ដូចជា ម៉ាស៊ីនត្រជាក់ ទូទឹកកក និងគ្រឿងអេឡិចត្រូនិកផ្សេងៗ មានកំណើនក្នុងអត្រា ២៨,២% និង ១៧,៣% និង ៥៤,២% រៀងគ្នា ក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០២៥ នេះ។ *អនុវិស័យដឹកជញ្ជូន និងស្តុក* ក៏ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយបន្តិច ក្នុងរង្វង់ ៥% ដោយសារការថមថយអនុវិស័យគាំទ្រ ដូចជា វិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាដើម។ ប៉ុន្តែ, អនុវិស័យនេះនៅបន្តរក្សាបាននិន្នាការវិជ្ជមាន ដែលបន្តទ្រទ្រង់ដោយការដឹកជញ្ជូនបែបរហ័ស (Express services) និង

សកម្មភាពដឹកជញ្ជូនក្នុងវិស័យទេសចរណ៍ គួបផ្សំនឹងការបន្តវិនិយោគហេដ្ឋារចនាសម្ព័ន្ធគាំទ្រ តួយ៉ាងដូចជា ការដាក់ឱ្យប្រើប្រាស់អាកាសយានដ្ឋានថ្មី និងការបន្តពង្រីកសមត្ថភាពផ្ទុករបស់កំពង់ផែទាំងពីរ។ ជាក់ស្តែង, គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥, បរិមាណកុងតឺន័រឆ្លងកាត់កំពង់ផែទាំងពីរ បានកើនក្នុងអត្រាប្រមាណ ២៤,១% ដែលក្នុងនោះ៖ កំពង់ផែស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ កើនប្រមាណ ២៦,២% និង ២៣,៣% រៀងគ្នា។ ជាមួយគ្នានេះ, ការនាំចូលប្រេងឥន្ធនៈ ពោលគឺប្រេងម៉ាស៊ូត និងប្រេងឥន្ធនៈសម្រាប់យន្តហោះ បានកើនក្នុងអត្រា ៥,១% និង ២៧,៤% រៀងគ្នា ក្នុងខណៈដែលការនាំចូលប្រេងសាំង ធ្លាក់ចុះក្នុងអត្រា ១០,៩% គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥។ *អនុវិស័យបច្ចេកវិទ្យា និងទូរគមនាគមន៍* នឹងត្រូវបានប៉ាន់ស្មានថានឹងបន្តកើនក្នុងអត្រាកំណើន ៧,១% ដែលគាំទ្រដោយការបន្តនិន្នាការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតស្ទើរតែលើគ្រប់វិស័យ និងគ្រប់ប្រភេទអាជីវកម្ម គួបផ្សំនឹងការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ *អនុវិស័យអចលនទ្រព្យ* ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយក្នុងរង្វង់ ២,៤% ដែលបន្តគាំទ្រដោយចរន្តទិញ-លក់លំនៅឋាន ជាពិសេសផ្នែកខុនដូ ដែលជំរុញដោយតម្រូវការក្នុងស្រុក ស្របពេលសកម្មភាពអចលនវត្ថុបម្រើឱ្យវិស័យឧស្សាហកម្ម (ការជួលរោងចក្រ និងដីធ្លី ជាពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស) នៅតែបន្តរក្សាបានចលនការរឹងមាំ ហើយចូលរួមគាំទ្រដល់អនុវិស័យនេះ។ ការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ជាពិសេសការលើកលែងពន្ធប្រថាប់ត្រាចំពោះលំនៅឋានថ្លៃក្រោម ៧ ម៉ឺនដុល្លារអាម៉េរិក និងការលើកលែងពន្ធប្រថាប់ត្រាចំពោះការទិញ-លក់ និង/ឬ ផ្ទេរកម្មសិទ្ធិលើកដំបូង (First-time home buyer) ចំពោះលំនៅឋានថ្លៃក្រោម ២១ ម៉ឺនដុល្លារអាម៉េរិក ដែលសុទ្ធសឹងជាវិធានការគាំទ្រផ្នែកតម្រូវការ ក៏នឹងបន្តជំរុញសកម្មភាពទិញ-លក់អចលនវត្ថុ ក្នុងឆ្នាំ ២០២៥ នេះ។ ជាក់ស្តែង, គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥, បរិមាណលក់ខុនដូ បានកើនឡើងគួរឱ្យកត់សម្គាល់ ប្រមាណ ១១២,៤% ជំរុញដោយតម្រូវការក្នុងស្រុក ពោលគឺការផ្លាស់ប្តូរនូវឥរិយាបថរស់នៅរបស់ប្រជាជន ជាពិសេសប្រជាជនជំនាន់ថ្មី។

(គ)-វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថានឹងរក្សាបានស្ថិរភាពកំណើន ក្នុងអត្រាប្រមាណ ០,៩% ដែលបន្តគាំទ្រដោយអនុវិស័យដំណាំ និងនេសាទ ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ រំពឹងថានឹងងើបឡើងវិញសន្សឹមៗ។ *អនុវិស័យដំណាំ* បន្តរក្សាស្ថិរភាពកំណើន ប៉ុន្តែក្នុងល្បឿនថមថយបន្តិច ក្នុងរង្វង់ ១,៤% ដោយសារការរំពឹងទុកការថមថយផលិតកម្មស្រូវ បណ្តាលមកពីការប្រែប្រួលថ្លៃលើទីផ្សារអន្តរជាតិ ត្បិតឥណ្ឌាចាប់ផ្តើមធ្វើការនាំចេញវិញ គួបផ្សំនឹងការរំពឹងទុកនៃការថមថយតម្រូវការពីទីផ្សាររបស់បណ្តាប្រទេសធំៗ ដូចជា ប្រទេសចិន ហ្វីលីពីន និងឥណ្ឌូនេស៊ី ដោយសារប្រទេសទាំងនោះបានបង្កើនផលិតកម្មស្រូវរបស់ខ្លួនសម្រាប់ដោះស្រាយបញ្ហាកង្វះស្បៀង។ យ៉ាងណាមិញ, ដំណាំសាកវប្បកម្ម និងឧស្សាហកម្មចម្បងផ្សេងទៀត នៅបន្តមានកំណើនល្អ និងទ្រទ្រង់ដល់កំណើននៃអនុវិស័យដំណាំនេះជារួម។ ជាមួយគ្នានេះ, អនុវិស័យនេះក៏ត្រូវបានគាំទ្រដោយវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដូចជា ការដាក់ចេញឱ្យអនុវត្តនូវ «កម្មវិធីធានាស្ថិរភាពថ្លៃកសិផល», «កម្មវិធីហិរញ្ញប្បទានក្រោមធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម» និង «ការពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ-សង្កាត់នៃគ្រប់បណ្តាខេត្ត» ជាដើម។ គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥ ការនាំចេញកសិផលសំខាន់ៗ មួយចំនួន ដូចជា ស្រូវ, អង្ករ, ពោតក្រហម, ចេក, ដំឡូងមី, ស្វាយ, និងស្វាយចន្ទី មានកំណើនល្អ ក្នុងអត្រា ៧,៧%, ១២,៩%, ១០១,២%, ១១,១%, ២៤,១%, ១១,៣%, និង ៣១,៧%

រៀងគ្នា ក្នុខណៈដែលផលិតផលមួយចំនួនទៀត រួមមាន កៅស៊ូ និងស្ករ បានធ្លាក់ចុះក្នុងអត្រា ២០,១% និង ៣១,១% រៀងគ្នា។ *អនុវិស័យចិញ្ចឹមសត្វ* ត្រូវបានប៉ាន់ស្មានថានឹងរក្សាកំណើនក្នុងអត្រា ០,២% ដោយសារការចាប់ផ្តើមងើបវិញនៃទំនុកចិត្តពីសំណាក់អ្នកចិញ្ចឹមសត្វ ស្របពេលដែលរាជរដ្ឋាភិបាលនៅតែបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើវិធានការអន្តរាគមន៍ និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងការនាំចូលសាច់បង្កក ដែលចូលរួមលើកកម្ពស់ផលិតកម្មក្នុងស្រុក។ *អនុវិស័យនេសាទ* ត្រូវបានប៉ាន់ស្មានថានឹងរក្សាកំណើនវិជ្ជមានក្នុងរង្វង់ ០,២% ដែលបន្តគាំទ្រដោយនិន្នាការល្អនៃផលចាប់ទឹកសាប ក្នុងខណៈដែលផលិតកម្មវារីវប្បកម្មនៅបន្តប្រឈមនឹងបញ្ហាទីផ្សារផ្គត់ផ្គង់នៅឡើយ។

**តារាងទី ២៖ កំណើនសេដ្ឋកិច្ចតាមវិស័យ ២០២២-២០២៥**

| កំណើនពិត | ២០២២ | ២០២៣ | ២០២៤ ប៉ាន់ | ២០២៥ ប៉ាន់ |
|---|---|---|---|---|
| **វិស័យកសិកម្ម** | **០,៦%** | **១,១%** | **០,៩%** | **០,៩%** |
| ដំណាំ | ១,១% | ១,២% | ១,៦% | ១,៤% |
| ការចិញ្ចឹមសត្វ | ១,២% | ១,១% | -១,៩% | ០,២% |
| នេសាទ | -១,៣% | ១,៣% | ០,៩% | ០,២% |
| ព្រៃឈើ | -២,៥% | -១,៣% | -១,៥% | -១,៨% |
| **វិស័យឧស្សាហកម្ម** | **៨,២%** | **៥,៤%** | **៩,២%** | **៧,១%** |
| កាត់ដេរ | ១១,៣% | -៤,៥% | ១៦,៩% | ១០,១% |
| សំណង់ | ០,៩% | ០,៨% | ១,១% | ២,៤% |
| កម្មន្តសាលមិនមែនកាត់ដេរ | ១,៣% | ២១,៧% | ៧,១% | ៦,៩% |
| **វិស័យសេវាកម្ម** | **៣,៦%** | **-៦,០%** | **៤,៥%** | **៣,៨%** |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | ២២,០% | ៤៩,១% | ១២,៩% | ៦,៩% |
| លក់ដុំ-រាយ | ៤,៥% | ២,១% | ៣,៩% | ៣,៤% |
| ដឹកជញ្ជូន និងស្តុក | -៤,៧% | ៤,៨% | ៧,២% | ៥,០% |
| បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ | ៩,០% | ៨,៦% | ៧,០% | ៧,១% |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | -១,០% | -០,១% | -០,៦% | ០,៩% |
| អចលនទ្រព្យ | ០,៥% | -១,៦% | ១,២% | ២,៤% |
| អនុវិស័យសេវាកម្មផ្សេងទៀត | ០,៨% | ៣,២% | ៣,៥% | ៣,៤% |
| **កំណើន ផសស ពិត** | **៥,១%** | **៥,០%** | **៦,០%** | **៥,០%** |

ក្នុងឆ្នាំ ២០២៥ កំណើននៃអត្រាអតិផរណា ត្រូវបានប៉ាន់ស្មានថានឹងងើបក្នុងរង្វង់ ៣,០%, មួយផ្នែក ឆ្លុះបញ្ចាំងពីមូលដ្ឋានទាបនៃឆ្នាំ ២០២៤, និងមួយផ្នែកទៀត, ដោយសារការបន្តកើនឡើងនៃសកម្មភាព ចាយវាយក្នុងស្រុក ខណៈដែលថ្លៃទំនិញអន្តរជាតិនៅបន្តមានស្ថានភាពតានតឹង។ គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥, អត្រាអតិផរណាស្ថិតក្នុងរង្វង់ប្រមាណ ៣,៥% ដែលម្ខាង, ដោយសារមូលដ្ឋានទាបពីឆ្នាំចាស់; និងម្ខាងទៀត, ដោយសារការងើបបន្តិចនៃថ្លៃម្ហូបអាហារ; ក្នុងខណៈដែលថ្លៃប្រេងឥន្ធនៈមាននិន្នាការធ្លាក់ចុះជាបន្តបន្ទាប់ ដោយសារប្រក្រតីភាពនៃថ្លៃប្រេងអន្តរជាតិ។ **អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក) រំពឹងថានឹងស្ថិតក្នុងរង្វង់ប្រមាណ ៤ ០៥៤ រៀល/ដុល្លារអាម៉េរិក** ដោយសារការបន្តបន្ធូរបន្ថយសម្ពាធនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក គួបផ្សំនឹងការបន្តអនុវត្តវិធានការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់។ ជាក់ស្តែង, ផ្អែកតាមទិន្នន័យពីធនាគារជាតិនៃកម្ពុជា, គិតត្រឹម ៦ ខែដើមឆ្នាំ ២០២៥ អត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់ប្រមាណ **៤ ០១០ រៀល/ដុល្លារអាម៉េរិក**។ ផ្អែកតាមការវាយតម្លៃឡើងវិញនេះ, ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ក្នុងឆ្នាំ ២០២៥ ត្រូវបានប៉ាន់ប្រមាណថានឹងរួមតូចក្នុងរង្វង់ -០,៤% នៃ ផ.ស.ស. ដោយសារការរំពឹងទុកពីការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏នៅបន្តមាននិន្នាការល្អ។

## ៣.៣- ហានិភ័យ និងបញ្ហាប្រឈម

ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២៥ នៅតែបន្តហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់នៃបរិការណ៍ខាងក្រៅ និងបញ្ហាប្រឈមខាងក្នុង ដូចខាងក្រោម៖

**ទី១-ផ្នែកក្រៅប្រទេស៖** សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យមួយចំនួន រួមមាន : ការបន្តកើននូវចរន្តគាំពារនិយម (Protectionism) ជាពិសេសពីប្រទេសមហាអំណាចនានា ពាក់ព័ន្ធគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម ឧទាហរណ៍ ការបន្តដំឡើងពន្ធគយ (Tariffs) ខ្ពស់ជាងការរំពឹងទុក និងភ្លាមៗ ដែលអាចមានភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ទច់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ, ការបិទខ្ទប់ច្រកព្រំដែនកម្ពុជា-ថៃ និងភាពតានតឹងនៃទំនាក់ទំនងទ្វេភាគីរបស់ប្រទេសទាំងពីរដែលប៉ះពាល់ដល់លំហូរពាណិជ្ជកម្ម និងទេសចរណ៍ក្នុងទ្រង់ទ្រាយធំជាងការរំពឹងទុក, លទ្ធភាពនៃការថមថយនៃសន្ទុះកំណើនសេដ្ឋកិច្ចសកល ជាពិសេសប្រទេសជាដៃគូពាណិជ្ជកម្ម និងប្រភពវិនិយោគ, ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម, ព្រមទាំងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិនានា។

**ទី២-ផ្នែកក្នុងស្រុក៖** ទន្ទឹមនឹងហានិភ័យខាងក្រៅ, កម្ពុជានៅបន្តប្រឈមនឹងបញ្ហាក្នុងស្រុកមួយចំនួនដែលមានចរិតជារចនាសម្ព័ន្ធ។ បញ្ហាប្រឈមទាំងនោះ រួមមាន : ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់, ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, ភាពមានកម្រិតនៃកម្លាំងពលកម្មជំនាញ ទាំងបរិមាណ និងគុណភាព ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ, ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និងភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

## ៣.៤- វិធានការផ្នែកម៉ាក្រូសេដ្ឋកិច្ច

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាព, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រម ចំនួន ២ នោះគឺ៖ (១). វិធានការគោលនយោបាយឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លី ដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធានាលំនឹងជីវភាពរបស់ប្រជាជន; និង (២). ទិសដៅវិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ ដែលនឹងផ្តោតលើការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ក្នុងការជំរុញការធ្វើពិពិធកម្ម ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់សម្រាប់សង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងនោះ, កម្ពុជាត្រូវយកចិត្តទុកដាក់លើឧបករណ៍វិធានការគោលនយោបាយដូចខាងក្រោម៖

១). **វិធានការគោលនយោបាយ** ដោះស្រាយបញ្ហាចំពោះមុខ ដោយផ្តោតលើការបន្តតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងរបបពាណិជ្ជកម្មសកល និងតំបន់ ព្រមទាំងក្តាប់ជីពចរសេដ្ឋកិច្ចក្នុងស្រុកឱ្យបានជាប្រចាំ, ខិតខំក្នុងការចរចាជាមួយភាគីសហរដ្ឋអាម៉េរិក ដើម្បីរកដំណោះស្រាយសមស្រប និងបន្តជំរុញការប្រើប្រាស់ឱ្យអស់សក្តានុពលនូវទីផ្សារមានស្រាប់ និងខិតខំបើកទីផ្សារថ្មី, ទាំងក្នុងក្របខ័ណ្ឌពហុភាគី និងទ្វេភាគី, តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ, ទាំងក្នុងតំបន់ និងក្រៅតំបន់, ក្នុងគោលដៅធ្វើពិពិធកម្មនៃការនាំចេញ និងពង្រឹងមូលដ្ឋានសេដ្ឋកិច្ច។

២). **វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ដោយផ្តោតលើការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលមានភាពប្រយ័ត្នប្រយែង និងធានាឱ្យបាននូវភាពបត់បែនខ្ពស់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃសភាពការណ៍ ហើយអាចធ្វើអន្តរាគមន៍បានភ្លាមៗ និងចំគោលដៅ ក្នុងករណីមានវិបត្តិ។ កិច្ចអន្តរាគមន៍ តាមរយៈវិធានការចំណាយថវិកា និងចំណាយសារពើពន្ធ នឹងត្រូវផ្តោតលើវិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងក្រុមដែលងាយរងគ្រោះ ដើម្បីធានានូវការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច ដែលមិនបង្កផលប៉ះពាល់ដល់ចីរភាពហិរញ្ញវត្ថុសាធារណៈ ខណៈបន្តពង្រឹងកិច្ចប្រឹងប្រែងកៀរគរចំណូល និងពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយ និងថវិកា ជាមួយនឹងការបន្តលើកកម្ពស់ប្រសិទ្ធភាពចំណាយ, ម្ខាង, ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍, និងម្ខាងទៀត, ក៏ធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ។

៣). **វិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ** ដោយផ្តោតលើគោលនយោបាយរូបិយវត្ថុដើម្បីទ្រទ្រង់កំណើន (Accommodative monetary policy) តាមរយៈការជំរុញកំណើនឥណទានក្នុងវិស័យដែលមានផលិតភាព (Productive sectors) ស្របជាមួយនឹងការបន្តតាមដាន និងវាយតម្លៃជាប្រចាំលើស្ថានភាពឥណទាន និងការរៀបចំឥណទានឡើងវិញ និងការបន្តតាមដាន និងគ្រប់គ្រងជាប្រចាំនូវស្ថានភាពថ្លៃ, អត្រាប្តូរប្រាក់ និងសុខុមាលភាពវិស័យហិរញ្ញវត្ថុជារួម, ពោលគឺទាំងផ្នែកធនាគារ និងមិនមែនធនាគារ ក្នុងគោលដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ និងបញ្ចៀសហានិភ័យជាប្រព័ន្ធ (Systemic risks)។

៤). **វិធានការគោលនយោបាយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ** តាមរយៈការពង្រឹងគ្រប់ការដ្ឋានកែទម្រង់គន្លឹះ៖ ការបន្តពង្រឹងយន្តការអនុវត្ត និងតាមដាន និងវាយតម្លៃ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»

រួមជាមួយការដាក់ចេញ និងអនុវត្តនូវ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ឆ្នាំ ២០២៥-២០២៨» និងគោលនយោបាយតាមវិស័យអាទិភាព។

## ៤- លទ្ធផលនៃការអនុវត្តថវិកាឆមាសទី ១ និងការវាយតម្លៃការអនុវត្តថវិកាសម្រាប់ឆ្នាំ ២០២៥

### ៤.១- ការអនុវត្តចំណូលឆមាសទី ១ ឆ្នាំ ២០២៥

ក-ចំណូលថ្នាក់ជាតិ

ចំណូលសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ នៅឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបានចំនួន ១៥ ២០០ ៣១៦ លានរៀល ស្មើនឹង ៥៣,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ គឺកើន ១៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ក្នុងនោះ៖

-ចំណូលចរន្ត អនុវត្តបានចំនួន ១៤ ៩៥៩ ០៣៥ លានរៀល ស្មើនឹង ៥៣,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺកើន ៨,១ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៥,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ គឺកើន ១៣,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលក្នុងនោះ **ចំណូលសារពើពន្ធ** អនុវត្តបានចំនួន ១៣ ១៣៤ ៩៧៤ លានរៀល ស្មើនឹង ៥៤,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ៨,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៥,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ គឺកើន ១២,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ និង **ចំណូលមិនមែនសារពើពន្ធ** អនុវត្តបានចំនួន ១ ៨២៤ ០៦២ លានរៀល ស្មើនឹង ៤៩,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ១,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៧,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់គឺកើនចំនួន ២៣,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។

ជារួម, ចំណូលសារពើពន្ធក្នុងឆ្នាំ ២០២៥ នេះ គឺអនុវត្តបានខ្ពស់ជាងឆ្នាំ ២០២៤ ធៀបនឹងរយៈពេល ៦ ខែដើមឆ្នាំដូចគ្នា ដោយសារទីផ្សារយានយន្តបានងើបវិញ និងអាករលើការនាំចេញខ្សាច់បន្តមានសកម្មភាពល្អ។ ទន្ទឹមគ្នានឹងការកើនឡើងនៃប្រភពចំណូលមួយចំនួន, ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងរវាងអាស៊ាន ជាមួយនឹងដៃគូអាស៊ានផ្សេងទៀត និងការលើកទឹកចិត្តពន្ធ និងអាករសម្រាប់គម្រោងវិនិយោគ និងវិស័យអាទិភាពនានា ក៏ធ្វើឱ្យប៉ះពាល់ដល់ចំណូលដែលត្រូវប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មួយផ្នែកផងដែរ។ ទោះជាយ៉ាងនេះក្ដី, តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ២០២៥, *ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ អាចនឹងសម្រេចបានត្រឹម ៩៧,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥, ពោលគឺទាបជាងច្បាប់ចំនួន ២,៦%*។ តាមការវាយតម្លៃនេះ, ចំណូលចរន្តនឹងសម្រេចបានទាបជាងផែនការ ១៧៩ លានដុល្លារអាម៉េរិក ដោយសារចំណូលពន្ធដារអាចសម្រេចបានទាបជាងផែនការ ៤៦៧ លានដុល្លារអាម៉េរិក និងចំណូលគយអាចខ្ពស់ជាងផែនការ ២៨៧ លានដុល្លារអាម៉េរិក និងចំណូលមិនមែនសារពើពន្ធនឹងសម្រេចខ្ពស់ជាងផែនការប្រមាណ ១ លានដុល្លារអាម៉េរិក។

ឯកតា៖ លានរៀល

| តារាងទី ៣៖ តារាងចំណូលថវិកាថ្នាក់ជាតិ | | | | | |
|---|---|---|---|---|---|
| **ប្រតិបត្តិការ** | ឆ្នាំ ២០២៥ | | | | |
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តឆមាសទី ១ | | ប៉ាន់ស្មានប្រចាំឆ្នាំ | |
| | | ទឹកប្រាក់ | %ច្ប. | ទឹកប្រាក់ | %ច្ប. |
| **I. ចំណូលឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ** | ២៨ ៤៨០ ០៦៣ | ១៥ ២០០ ៣១៦ | ៥៣,៤% | ២៧ ៧៧៥ ៨៥៧ | ៩៧,៥% |
| ១. ចំណូលចរន្ត | ២៧ ៨៦៩ ៤០៣ | ១៤ ៩៥៩ ០៣៥ | ៥៣,៧% | ២៧ ១៤៧ ៥៦៦ | ៩៧,៤% |
| ក. ចំណូលសារពើពន្ធ | ២៤ ១៩៩ ៣៧១ | ១៣ ១៣៤ ៩៧៤ | ៥៤,៣% | ២៣ ៤៧២ ៦៧៨ | ៩៧,០% |
| - ចំណូលពន្ធ និងអាករគយ | ១០ ១៤៥ ៦៨០ | ៥ ៩៤៨ ៩១៣ | ៥៨,៦% | ១១ ៣០៩ ៥១៥ | ១១១,៥% |
| - ចំណូលពន្ធដារ | ១៤ ០៥៣ ៦៩១ | ៧ ១៨៦ ០៦១ | ៥១,១% | ១២ ១៦៣ ១៦២ | ៨៦,៥% |
| ខ. ចំណូលមិនមែនសារពើពន្ធ | ៣ ៦៧០ ០៣២ | ១ ៨២៤ ០៦២ | ៤៩,៧% | ៣ ៦៧៤ ៨៨៨ | ១០០,១% |
| - ចំណូលពីទ្រព្យសម្បត្តិរដ្ឋ (អគ្គ.ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) | ៧១០ ៣១២ | ២៨១ ២៨៤ | ៣៩,៦% | ៦៣៩ ៥៩៨ | ៩០,០% |
| - ចំណូលមិនមែនសារពើពន្ធ (អគ្គ.ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) | ២ ៧៤២ ៥៩២ | ១ ៣៨៦ ៥៩៨ | ៥០,៦% | ២ ៨២០ ៥៧២ | ១០២,៨% |
| - ចំណូលមិនមែនសារពើពន្ធផ្សេងៗ (ចំណូលពីកាតព្វកិច្ចល្បែង) | ២១៧ ១២៨ | ១៥៦ ១៨០ | ៧១,៩% | ២១៤ ៧១៨ | ៩៨,៩% |
| ២. ចំណូលផ្សេងៗ | ៦១០ ៦៦០ | ២៤១ ២៨១ | ៣៩,៥% | ៦២៨ ២៩១ | ១០២,៩% |
| -ក្នុងប្រទេស | ៥៤៩ ៩៨០ | ២០៤ ៩៨៧ | ៣៧,៣% | ៥៤៩ ៩៨០ | ១០០,០% |
| -មូលនិធិទ្រទ្រង់ថវិកា | ៦០ ៦៨០ | ៣៦ ២៩៤ | ៥៩,៨% | ៧៨ ៣១១ | ១២៩,១% |

-ចំណូលផ្សេងៗ អនុវត្តបានចំនួន ២៤១ ២៨១ លានរៀល គឺស្មើនឹង ៣៩,៥% នៃច្បាប់ហិរញ្ញវត្ថុ។ ក្នុងនោះ ចំណូលផ្សេងៗក្នុងប្រទេស អនុវត្តបានចំនួន ២០៤ ៩៨៧ លានរៀល ស្មើនឹង ៣៧,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាង ៣,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤០,៨% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារគម្រោងមួយចំនួន មានកម្មវិធីសងតែ ១ ដង ក្នុងមួយឆ្នាំ គឺនៅឆមាសទី ២។ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ, ចំណូលផ្សេងៗក្នុងប្រទេស អាចសម្រេចបានប្រមាណ ១០០% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។ ចំពោះចំណូលមូលនិធិទ្រទ្រង់ថវិកា អនុវត្តបានចំនួន ៣៦ ២៩៤ លានរៀល ស្មើនឹង ៥៩,៨% នៃច្បាប់ហិរញ្ញវត្ថុ នៅត្រឹមឆមាសទី ១ នេះ។

ក.១-ចំណូលសារពើពន្ធ សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបាន ៥៤,៣% នៃច្បាប់ហិរញ្ញវត្ថុ ដែលក្នុងនោះ៖

- ចំណូលពន្ធ និងអាករគយ អនុវត្តបានចំនួន ៥ ៩៤៨ ៩១៣ លានរៀល ស្មើនឹង ៥៨,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ១៦,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤២,១% នៃច្បាប់ហិរញ្ញវត្ថុ។ ជាការសម្គាល់ឃើញថា ទីផ្សាររថយន្តបានងើបវិញ ក៏ប៉ុន្តែ មានភាពធូរស្បើយ

អាស្រ័យលើស្ថិរភាពសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក និងរំហូរនៃការវិនិយោគ ជាដើម។ ផលិតកម្មក្នុងស្រុក និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក៏ជាមូលហេតុនៃការប៉ះពាល់ដល់ការប្រមូលចំណូលរបស់គយផងដែរ។ ចំណូលបាត់បង់ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងរវាងអាស៊ានជាមួយដៃគូអាស៊ានផ្សេងទៀត សរុបក្នុងឆមាសទី ១ ឆ្នាំ ២០២៥ មានរហូតដល់ ១ ០១០ ០៧០ លានរៀល កើន ១២,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ទន្ទឹមនេះ, ការលើកទឹកចិត្តពន្ធនិងអាករសម្រាប់គម្រោងវិនិយោគ និងវិស័យអាទិភាពនានា បានកើនប្រមាណ ២១,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។

បើពិនិត្យលើរចនាសម្ព័ន្ធពន្ធអាករដែលប្រមូលបានឃើញថា (១)-ពន្ធលើការនាំចូលអនុវត្តបាន ៤៨,៨% នៃផែនការច្បាប់, (២)-អាករលើការនាំចេញអនុវត្តបាន ១២១,១% នៃផែនការច្បាប់ ដោយសារការនាំចេញខ្សាច់បន្តមានសកម្មភាពល្អ (៣)-អាករពិសេសលើទំនិញមួយចំនួននៃរបបនាំចូលអនុវត្តបាន ៦៣,៣% នៃផែនការច្បាប់ និង (៤)-អាករលើតម្លៃបន្ថែមនៃរបបនាំចូលអនុវត្តបាន ៥៧,២% នៃផែនការច្បាប់។

ទន្ទឹមនេះ, បើពិនិត្យលើប្រភពចំណូលសំខាន់ៗ នោះឃើញថា៖

- **ចំណូលពីមុខទំនិញយានយន្តនិងគ្រឿងចក្រ** ដែលគ្របដណ្តប់ប្រមាណ ៣៦,២% នៃចំណូលសរុប បានកើន ៥០,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤
- **ចំណូលពីមុខទំនិញចម្រុះ** ដែលគ្របដណ្តប់ប្រមាណ ៣២,៣% នៃចំណូលសរុប បានកើន ១៣,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤
- **ចំណូលពីមុខទំនិញផលិតផលតេលសិលា** ដែលគ្របដណ្តប់ប្រមាណ ២៣,៧% នៃចំណូលសរុប បានថយចុះ -១,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤
- **ចំណូលពីមុខទំនិញគ្រឿងសំណង់** ដែលគ្របដណ្តប់ប្រមាណ ៦,៣% នៃចំណូលសរុប បានកើន ៣១,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤
- **កម្រៃនិងចំណូលផ្សេងៗ** ដែលគ្របដណ្តប់ប្រមាណ ១,៥% នៃចំណូលសរុប បានកើន ៦,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។

ជារួម, ការប្រមូលចំណូលគយនិងរដ្ឋាករ ក្នុងឆមាសទី ១ ឆ្នាំ ២០២៥ មាននិន្នាការកើន និងតាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ, **ចំណូលគយ និងរដ្ឋាករអាចនឹងសម្រេចបានប្រមាណ ១១១,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។**

• ចំណូលពន្ធដារ (ថ្នាក់ជាតិ) អនុវត្តបានចំនួន ៧ ១៨៦ ០៦១ លានរៀល **ស្មើនឹង ៥១,១%** នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាង ៣,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៧,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ ចំណូលពន្ធដារកើន ២,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ គឺដោយសារ៖

- ពន្ធលើប្រាក់ចំណូល, ដែលគ្របដណ្តប់ប្រមាណ ៥១% នៃចំណូលពន្ធដារថវិកាថ្នាក់ជាតិសរុប, អនុវត្តបាន ៥៦,៣% នៃច្បាប់ហិរញ្ញវត្ថុ,
- ពន្ធលើប្រាក់បៀវត្ស, ដែលគ្របដណ្តប់ប្រមាណ ១២% នៃចំណូលពន្ធដារថវិកាថ្នាក់ជាតិសរុប, អនុវត្តបាន ៤៥,៩% នៃច្បាប់ហិរញ្ញវត្ថុ,

- អាករលើតម្លៃបន្ថែម (របបផ្ទៃក្នុង), ដែលគ្របដណ្តប់ប្រមាណ ២៧% នៃចំណូលពន្ធដារថវិកាថ្នាក់ជាតិសរុប, អនុវត្តបាន ៤៩,៦% នៃច្បាប់ហិរញ្ញវត្ថុ,

- អាករពិសេសលើទំនិញ និងសេវាក្នុងស្រុក, ដែលគ្របដណ្តប់ប្រមាណ ៩% នៃចំណូលពន្ធដារថវិកាថ្នាក់ជាតិសរុប, អនុវត្តបាន ៣៣,៨% នៃច្បាប់ហិរញ្ញវត្ថុ។

ជារួម, ការប្រមូលចំណូលពន្ធដារនៅឆមាសទី ១ ឆ្នាំ ២០២៥ គឺអនុវត្តបានខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដោយសារចំណូលពីពន្ធលើប្រាក់ចំណូល និងអាករលើតម្លៃបន្ថែមមានកំណើនល្អ។ *ទោះជាយ៉ាងនេះក្តី, តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ, ចំណូលពន្ធដារ (ថ្នាក់ជាតិ) អាចនឹងសម្រេចបានប្រមាណ ៨៦,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ប៉ុណ្ណោះ* ដោយហេតុថា ការបន្តថមថយនៃពន្ធលើប្រាក់ចំណូល, អាករលើតម្លៃបន្ថែម និងអាករពិសេស ខណៈចំណូលពីវិស័យមួយចំនួន រួមមាន វិស័យសាងសង់ និងអចលនទ្រព្យ ត្រូវបានរំពឹងទុកថានឹងបន្តមានកំណើនយឺត គួបផ្សំជាមួយនឹងការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តនានា។

ក.២-ចំណូលមិនមែនសារពើពន្ធ អនុវត្តបានចំនួន ១ ៨២៤ ០៦២ លានរៀល ស្មើនឹង ៤៩,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាង ១,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបានចំនួន ៤៧,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានការកើន ២៣,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ (បើគិតជាចំណូលមិនមែនសារពើពន្ធដែលកត់ត្រាតាមប្រព័ន្ធ NRMIS, ចំណូលមិនមែនសារពើពន្ធ នៅឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបាន ១ ៩៨៥ ៣៨៦ លានរៀល ស្មើនឹង ៥៤,១% នៃច្បាប់ហិរញ្ញវត្ថុ) ក្នុងនោះ៖

- ចំណូលពីទ្រព្យសម្បត្តិរដ្ឋ អនុវត្តបានចំនួន ២៨១ ២៨៤ លានរៀល ស្មើនឹង ៣៩,៦% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាង ១,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៣៧,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់កើន ២៣,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ប្រសិនបើពិនិត្យលើមុខសញ្ញាចំណូលជាក់លាក់មួយចំនួន នោះឃើញថា ចំណូលពីសម្បទានប្រេងកាត និងរ៉ែ, ផលព្រៃឈើ, ប្រាក់ចំណេញសហគ្រាសសាធារណៈ និងចំណូលផ្សេងៗ អនុវត្តបានល្អប្រសើរ ដោយមានកំណើន ៥១,៩%, ១៣៣,៦%, ៦,៦%, ៥៧,១% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលជាលទ្ធផលការពង្រឹងយន្តការនៃការប្រមូលចំណូលតាមវិស័យនីមួយៗ លើកលែងតែចំណូលពីការជួលអចលនវត្ថុ មានការធ្លាក់ចុះ ៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។
- ចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ អនុវត្តបាន ៥០,៦% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាង ០,៦ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៥០% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានការកើនចំនួន ២០,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ប្រសិនបើពិនិត្យលើមុខសញ្ញាចំណូលជាក់លាក់មួយចំនួន នោះឃើញថា ចំណូលពីផលទុនរបស់អាកាសចរណ៍ស៊ីវិល, ផលទុននៃសកម្មភាពទេសចរណ៍, ផលទុនរបស់ប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាករនៃស្ថានទូត អនុវត្តបានល្អប្រសើរ ដោយមានកំណើន ៣៨%, ៤,៦%, ១៧,៧%, ៣១,២% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ លើកលែងតែចំណូលពីកម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ មានការធ្លាក់ចុះ ៤០,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។

ដោយឡែក, ចំណូលពីកាតព្វកិច្ចល្បែងកាស៊ីណូ និងចំណូលពីកាតព្វកិច្ចល្បែងផ្សងសំណាងអនុវត្តបានចំនួន ១៥៦ ១៨០ លានរៀល ស្មើនឹង ៧១,៩% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាង ១៥,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៥៦,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ចំណូលនេះមានការកើន ៥៥,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ចំណូលនេះ មានការកើនក្នុងឆមាសទី ១ ឆ្នាំ ២០២៥ ដោយសារតែកាស៊ីណូណាហ្គាវើលដ៍ ខំផ្លិកស៍ បានបង់បំណុល និងកាស៊ីណូមួយចំនួនបានបង់បន្ថែមនូវចំណូលកាតព្វកិច្ចពីល្បែងដែលបានបង់ខ្វះ តាមរយៈការធ្វើសវនកម្មប្រចាំឆ្នាំ, ក៏ប៉ុន្តែ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ២០២៥ ចំណូលពីកាតព្វកិច្ចល្បែងកាស៊ីណូ និងចំណូលពីកាតព្វកិច្ចល្បែងផ្សងសំណាង អាចសម្រេចបានប្រមាណ ៩៨,៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ដោយសារក្រុមហ៊ុនផ្សងសំណាងមួយចំនួនបានព្យួរអាជ្ញាបណ្ណ។

ជារួម, ចំណូលមិនមែនសារពើពន្ធ ដែលមានបីផ្នែកសំខាន់ៗ រួមមាន៖ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងចំណូលកាតព្វកិច្ចពីកាស៊ីណូនិងចំណូលកាតព្វកិច្ចពីឆ្នោតក្នុងឆមាសទី ១ នៅឆ្នាំ ២០២៥ អនុវត្តបានល្អប្រសើរ និងតាមការប៉ាន់ស្មាន រហូតដល់ដំណាច់ឆ្នាំ ២០២៥, ចំណូលមិនមែនសារពើពន្ធ អាចនឹងសម្រេចបានប្រមាណ ១០០,១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

ខ-ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

• ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបានចំនួន ១ ៧៥២ ៨៧៧ លានរៀល ស្មើនឹង ៣៩,៦% នៃច្បាប់ហិរញ្ញវត្ថុ, គឺប្រហាក់ប្រហែលនឹងការអនុវត្តធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤, ក្នុងនោះ៖

- ចំណូលសារពើពន្ធ អនុវត្តបានចំនួន ៧៤៥ ២៣៨ លានរៀល ស្មើនឹង ៣៣,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ថយចំនួន ២,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។
- ចំណូលមិនមែនសារពើពន្ធ អនុវត្តបានចំនួន ១០៩ ២៣០ លានរៀល ស្មើនឹង ៣៦,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់កើនចំនួន ១,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។
- ចំណូលផ្សេងៗ
  + ចំណូលឧបត្ថម្ភធនពីថវិការដ្ឋ អនុវត្តបានចំនួន ៨៧៧ ១៧៣ លានរៀល ស្មើនឹង ៤៦,៩% នៃច្បាប់ហិរញ្ញវត្ថុ។
  + ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តបានចំនួន ២១ ២៣៦ លានរៀល ស្មើនឹង ៦៤,៩% នៃច្បាប់ហិរញ្ញវត្ថុ។

ជារួម, ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២៥ នេះ អនុវត្តមិនទាន់បានល្អនៅឡើយ និងត្រូវបានប៉ាន់ស្មានថារហូតដល់ដំណាច់ឆ្នាំ ២០២៥ ចំណូលថ្នាក់ក្រោមជាតិ អាចនឹងសម្រេចទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៧,៥% ដោយចំណូលសារពើពន្ធអាចនឹងសម្រេចបានទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១៥,១%។ ការថមថយនេះ គឺបណ្តាលមកពីការធ្លាក់ចុះចំណូលពន្ធប្រថាប់ត្រា ជាពិសេសដោយសារការបន្តការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមានតម្លៃទាបជាង ឬស្មើ ៧ ម៉ឺនដុល្លារអាមេរិក, ការធ្លាក់ចុះចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់, ការធ្លាក់ចុះចំណូលអាករបំភ្លឺសាធារណៈ និងការធ្លាក់ចុះប្រភេទពន្ធមួយចំនួនទៀតពាក់ព័ន្ធនឹងចំណូលថ្នាក់ក្រោមជាតិ។

ឯកតា៖ លានរៀល

## តារាងទី ៤៖ តារាងចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ប្រតិបត្តិការ | ឆ្នាំ ២០២៥ | | | | |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តឆមាសទី ១ | | ប៉ាន់ស្មានប្រចាំឆ្នាំ | |
| | | ទឹកប្រាក់ | %ច្ប. | ទឹកប្រាក់ | %ច្ប. |
| **សរុបចំណូលថវិកាថ្នាក់ក្រោមជាតិ** | ៤ ៤២១ ៥៨០ | ១ ៧៥២ ៨៧៧ | ៣៩,៦% | ៤ ០៨៨ ៣២៩ | ៩២,៥% |
| -សរុបចំណូលចរន្ត | ២ ៥១៩ ៤៧៤ | ៨៥៤ ៤៦៨ | ៣៣,៩% | ២ ១៨៣ ៩៧៣ | ៨៦,៧% |
| ចំណូលសារពើពន្ធ (ប្រមូលដោយអគ្គ.ពន្ធដារ) | ២ ២១៨ ៧៣៩ | ៧៤៥ ២៣៨ | ៣៣,៦% | ១ ៨៨២ ៩៧៣ | ៨៤,៩% |
| ចំណូលមិនមែនសារពើពន្ធ | ៣០០ ៧៣៥ | ១០៩ ២៣០ | ៣៦,៣% | ៣០១ ០០០ | ១០០,១% |
| -សរុបចំណូលផ្សេងៗ | ១ ៩០២ ១០៦ | ៨៩៨ ៤០៩ | ៤៧,២% | ១ ៩០៤ ៣៥៦ | ១០០,១% |
| ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ | ១ ៨៦៩ ៣៧០ | ៨៧៧ ១៧៣ | ៤៦,៩% | ១ ៨៧១ ៦២០ | ១០០,១% |
| ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ៣២ ៧៣៦ | ២១ ២៣៦ | ៦៤,៩% | ៣២ ៧៣៦ | ១០០,០% |
| **ក-ចំណូលថវិការាជធានី ខេត្ត** | ២ ៥៣៦ ២០៧ | ៨៧៣ ៦៧៥ | ៣៤,៤% | ២ ២០២ ៣៨០ | ៨៦,៨% |
| -ចំណូលចរន្ត | ២ ៥០៧ ៤៥៥ | ៨៥១ ៤៤៩ | ៣៤,០% | ២ ១៧១ ៣៧៨ | ៨៦,៦% |
| ចំណូលសារពើពន្ធ (ប្រមូលដោយអគ្គ.ពន្ធដារ) | ២ ២១៨ ៧៣៩ | ៧៤៥ ២៣៨ | ៣៣,៦% | ១ ៨៨២ ៩៧៣ | ៨៤,៩% |
| ចំណូលមិនមែនសារពើពន្ធ | ២៨៨ ៧១៦ | ១០៦ ២១១ | ៣៦,៨% | ២៨៨ ៤០៥ | ៩៩,៩% |
| -ចំណូលផ្សេងៗ | ២៨ ៧៥២ | ២២ ២២៦ | ៧៧,៣% | ៣១ ០០២ | ១០៧,៨% |
| ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ | ១៣ ០៥២ | ៦ ៥២៦ | ៥០,០% | ១៥ ៣០២ | ១១៧,២% |
| ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៥ ៧០០ | ១៥ ៧០០ | ១០០,០% | ១៥ ៧០០ | ១០០,០% |
| **ខ-ចំណូលថវិកាក្រុង ស្រុក** | ៥៨៧ ៧៣១ | ២២៩ ៨០៦ | ៣៩,១% | ៥៨៧ ៧៣១ | ១០០,០% |
| -ចំណូលចរន្ត | ១២ ០១៩ | ២ ៤៤៣ | ២០,៣% | ១២ ០១៩ | ១០០,០% |
| ចំណូលមិនមែនសារពើពន្ធ | ១២ ០១៩ | ២ ៤៤៣ | ២០,៣% | ១២ ០១៩ | ១០០,០% |
| -ចំណូលផ្សេងៗ | ៥៧៥ ៧១២ | ២២៧ ៣៦៣ | ៣៩,៥% | ៥៧៥ ៧១២ | ១០០,០% |
| ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ | ៥៥៨ ៦៧៦ | ២២១ ៨២៧ | ៣៩,៧% | ៥៥៨ ៦៧៦ | ១០០,០% |
| ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៧ ០៣៦ | ៥ ៥៣៦ | ៣២,៥% | ១៧ ០៣៦ | ១០០,០% |
| **គ-ចំណូលថវិកាឃុំ សង្កាត់** | ១ ២៩៧ ៦៤២ | ៦៤៩ ៣៩៦ | ៥០,០% | ១ ២៩៨ ២១៨ | ១០០,០% |
| -ចំណូលចរន្ត | | ៥៧៦ | - | ៥៧៦ | - |
| ចំណូលមិនមែនសារពើពន្ធ | | ៥៧៦ | - | ៥៧៦ | - |
| -ចំណូលផ្សេងៗ | ១ ២៩៧ ៦៤២ | ៦៤៨ ៨២០ | ៥០,០% | ១ ២៩៧ ៦៤២ | ១០០,០% |
| ឧបត្ថម្ភថវិកាពីថ្នាក់ជាតិ | ១ ២៩៧ ៦៤២ | ៦៤៨ ៨២០ | ៥០,០% | ១ ២៩៧ ៦៤២ | ១០០,០% |

## ៤.២- ការប៉ាន់ស្មាន និងការវាយតម្លៃលើការអនុវត្តចំណូលថវិកាឆ្នាំ ២០២៥

ជារួម, ផ្អែកលើលទ្ធផលដែលសម្រេចបានក្នុងឆមាសទី ១ និងនិន្នាការប្រមូលចំណូលឆមាសទី ២ ខាងមុខនេះ, អាចសន្និដ្ឋានបានថា **ការអនុវត្តចំណូលទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥ អាចនឹងសម្រេចបានទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ប្រមាណ ៣,៣%** ដោយក្នុងនោះ៖

- ចំណូលចរន្តអាចនឹងសម្រេចទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៣,៥% ដោយសារចំណូលសារពើពន្ធអាចនឹងសម្រេចទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៤%, ចំណែកឯចំណូលមិនមែនសារពើពន្ធ អាចនឹងសម្រេចខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ០,១%, និង
- ចំណូលផ្សេងៗថវិកាជាតិ ត្រូវបានប៉ាន់ស្មានថានឹងអាចអនុវត្តបានចំនួន ១ ២២៦ ៨២៧ លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១,៥%។

ជាមួយនឹងស្ថានភាពនៃការថមថយចំណូលឆ្នាំ ២០២៥ តាមការវាយតម្លៃខាងលើ ផ្អែកចំណូលនេះមាន **បញ្ហាប្រឈម និង ហានិភ័យ** មួយចំនួន ដូចខាងក្រោម៖

-<u>ផ្នែកចំណូលពន្ធដារ</u>

- ការបន្តថមថយនៃចំណូលពន្ធសំខាន់ៗក្នុងឆ្នាំ ២០២៥ ដូចជា ពន្ធលើប្រាក់ចំណូល, ចំណូលពន្ធប្រយោល (អាករលើតម្លៃបន្ថែម និងអាករពិសេស) និងចំណូលពន្ធថ្នាក់ក្រោមជាតិ ខណៈចំណូលពីវិស័យមួយចំនួនទៀត រួមមាន វិស័យសាងសង់ និងអចលនទ្រព្យ ត្រូវបានរំពឹងទុកថានឹងបន្តមានកំណើនយឺតគួបផ្សំជាមួយនឹងការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តនានា,
- ចំណូលពន្ធបន្តប្រឈមនឹងភាពមិនប្រាកដប្រជា ស្របពេលដែលកត្តាខាងក្រៅអាចប៉ះជាអវិជ្ជមានលើវិស័យជាប្រភពចំណូលដែលកំពុងងើបវិញសន្សឹមៗ,
- ការថមថយនូវកំណើនសេដ្ឋកិច្ច និងសកម្មភាពអាជីវកម្មសកលលោក,
- បញ្ហាពាក់ព័ន្ធ និងការអនុវត្តអាករលើតម្លៃបន្ថែមលើផលិតផលនាំចូលដែលត្រូវបានចាត់ជាបន្ទុករបស់រដ្ឋ,
- កង្វះខាតនូវយន្តការគ្រប់គ្រងក្នុងការប្រមូលទិន្នន័យ (ដូចជា Payment Gateway) ដើម្បីពង្រីកវិសាលភាពមូលដ្ឋានចំណូលពន្ធពីវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- ផលប៉ះពាល់មួយចំនួនដែលកើតឡើងពីការបំភ្លៃស្ថានភាពពិត ដោយភ្នាក់ងារផ្តល់សេវាគណនេយ្យ និងពន្ធដារមួយចំនួន ដែលបានផ្សព្វផ្សាយទៅដល់វិនិយោគិន,
- សកម្មភាពអាជីវកម្មមួយចំនួនមានកម្រិតផលរបរខ្ពស់ ប៉ុន្តែជ្រកក្រោមរូបភាពជាអាជីវកម្មខ្នាតតូច,
- វិស័យមួយចំនួនដែលធ្លាប់បានរួមចំណែកខ្ពស់ក្នុងការប្រមូលចំណូលពន្ធមាននិន្នាការថមថយ,
- បញ្ហាការផលិតនិងចែកចាយនូវផលិតផលសុរានិងថ្នាំជក់ក្លែងក្លាយ និងគេចពន្ធនានា,
- វិស័យអចនលទ្រព្យនៅតែបន្តជួបបញ្ហាប្រឈមនៅឡើយ ស្របពេលជាមួយនឹងសេដ្ឋកិច្ចសកលនៅតែបន្តជួបវិបត្តិ ដែលជាប្រការដាក់កំហិតដល់ការពង្រីកការប្រមូលពន្ធលើអចលនទ្រព្យ។

-<u>ផ្នែកចំណូលពន្ធ និង អាករគយ</u>

- ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ, ការប្រែប្រួលនៃរំហូរពាណិជ្ជកម្ម និងការវិនិយោគ, ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ បានធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម,

• ការបន្តកើននៃវិនិយោគផ្ដុំដំឡើងរថយន្តនិងទោចក្រយានយន្ត, កំណើនផលិតកម្មក្នុងស្រុកជំនួសឱ្យទំនិញនាំចូល និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ក៏បានប៉ះពាល់ដល់ចំណូលគយមួយផ្នែក,

• ការអនុវត្តច្បាប់វិនិយោគថ្មីមានវិសាលភាពគ្របដណ្ដប់មុខសញ្ញាទំនិញដែលជាកម្មវត្ថុនៃការអនុគ្រោះពន្ធ និងអាករកាន់តែធំ និងការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគរបស់រាជរដ្ឋាភិបាល,

• និន្នាការកើនឡើងនៃការប្រើប្រាស់រថយន្តអគ្គិសនី និងរថយន្តដែលមានទំហំស៊ីឡាំងតូច,

• ការបន្តកើតមានឡើងនូវការគេចវេះ និងបន្លំពន្ធដែលមានលក្ខណៈជាប្រព័ន្ធ និងស្មុគស្មាញ,

• និន្នាការកើនឡើងនៃការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក ដែលបង្កការលំបាកដល់ការគ្រប់គ្រង,

• ភាពកាន់តែស្រួចស្រាវនៃសង្គ្រាម (នៅអ៊ុយក្រែន និងនៅមជ្ឈិមបូព៌ា) បានបង្កផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ជាពិសេសគឺភាពរអាក់រអួលនៃខ្សែប្រវាក់ផ្គត់ផ្គង់ជាអន្តរជាតិ,

• ការអនុវត្តពន្ធបដិការរបស់សហរដ្ឋអាម៉េរិកមកលើកម្ពុជា,

• ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចកំពុងកាត់បន្ថយនូវការចូលរួមក្នុងចរន្តសកលភាវូបនីយកម្មស្របជាមួយនឹងការដាក់សម្ពាធ និងលក្ខខណ្ឌពាណិជ្ជកម្ម និងសេដ្ឋកិច្ចរបស់បណ្ដាប្រទេសមហាអំណាច,

• ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ ការប្រែប្រួលនៃលំហូរពាណិជ្ជកម្មនិងការវិនិយោគ ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ បានធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មជាសកល។

-<u>ផ្នែកចំណូលមិនមែនសារពើពន្ធ</u>

- ចំណូលពីវិស័យទេសចរណ៍ នៅមិនទាន់មានភាពច្បាស់លាស់ ដោយកត្តាពីខាងក្រៅប្រទេស,
- ការប្រមូលចំណូលមិនទាន់អស់សក្ដានុពល ដែលបណ្ដាលមកពីការកែសម្រួលមួយចំនួនលើផ្នែកច្បាប់ គោលការណ៍ និងយន្តការស្ថាប័ន ដូចជាចំណូលវិស័យទូរគមនាគមន៍ និងធនធានរ៉ែមួយចំនួន,
- ការប្ដេជ្ញាចិត្ត និងភាពម៉ឺងម៉ាត់ ក្នុងកិច្ចសហការប្រទាក់ក្រឡារវាងអន្តរក្រសួង នៅមានកម្រិត,
- កង្វះភាពប្រទាក់ក្រឡា សម្រាប់តាមដានវឌ្ឍនភាព និងវាយតម្លៃការអនុវត្តចំណូលឱ្យកាន់តែមានប្រសិទ្ធភាព,
- យន្តការទំនាក់ទំនង សមត្ថភាព និងការទទួលខុសត្រូវ នៅមានកម្រិត,
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅមិនទាន់បានកែលម្អគ្រប់គ្រាន់ ទន្ទឹមនឹងការអនុវត្តនៅខ្វះចន្លោះ,
- ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រង នៅមានកម្រិត ដោយត្រូវធ្វើទំនើបកម្មបន្ថែម និងពង្រីកវិសាលភាពទាំងការប្រើប្រាស់ និងការកសាងប្រព័ន្ធ,
- ការស្វែងរកប្រភពចំណូលថ្មីៗ នៅជួបការលំបាក ដោយមានភាពស្មុគស្មាញ ក្នុងការសម្របសម្រួលពីអន្តរក្រសួង ស្ថាប័ន និងភូមិសាស្ត្រ ព្រមទាំងសមត្ថភាពមន្ត្រី និងប្រសិទ្ធភាពស្ថាប័ននៅមានកម្រិត។

## ៤.៣- ការអនុវត្តចំណាយឆមាសទី ១ ឆ្នាំ ២០២៥

### ក-ចំណាយថ្នាក់ជាតិ

ក.១-ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ នៅឆមាសទី ១ ឆ្នាំ ២០២៥, តាមអាណត្តិបើកប្រាក់ (មិនទាន់គិតបុរេប្រទាន) អនុវត្តបានចំនួន ១៤ ៦៤៧ ៩៣៥ លានរៀល ស្មើនឹង ៥១,៣% នៃ

ច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៦,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ១០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ក្នុងនោះ **ចំណាយចរន្ត** អនុវត្តបានចំនួន ១២ ៧០៤ ០៦៨ លានរៀល ស្មើនឹង ៥៣,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៨,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ១០,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ទន្ទឹមនេះ, **ចំណាយមូលធន** អនុវត្តបានចំនួន ១ ៩៤៣ ៨៦៦ លានរៀល ស្មើនឹង ៤២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៣ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៣៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើន ១១,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ *បើគិតទាំងចំណាយតាមបុរេប្រទាន ដែលមានចំនួនប្រមាណ ៩៣០ ៦០៤ លានរៀល (ចំណាយចរន្ត និងចំណាយមូលធន) ផង, ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ នៅឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបានចំនួន ១៥ ៥៧៨ ៥៣៩ លានរៀល ស្មើនឹង ៥៤,៦% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ ចំណាយចរន្តអនុវត្តបានចំនួន ៥៦% នៃច្បាប់ហិរញ្ញវត្ថុ និងចំណាយមូលធនអនុវត្តបានចំនួន ៤៧,៣% នៃច្បាប់ហិរញ្ញវត្ថុ។*

ឯកតា៖ លានរៀល

**តារាងទី ៥៖ តារាងចំណាយថវិកាថ្នាក់ជាតិឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ**

| ប្រតិបត្តិការ | ឆ្នាំ ២០២៥ | | | | |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តឆមាសទី ១ | | ប៉ាន់ស្មានប្រចាំឆ្នាំ | |
| | | ទឹកប្រាក់ | %ច្ប. | ទឹកប្រាក់ | %ច្ប. |
| II. ចំណាយឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ | ២៨ ៥២៦ ៩០៥ | ១៥ ៥៧៨ ៥៣៩ | ៥៤,៦% | ២៨ ៦៦៨ ៥៨០ | ១០០,៥% |
| ១. ចំណាយចរន្ត | ២៣ ៩០១ ៨០៩ | ១៣ ៣៩៣ ០៣១ | ៥៦,០% | ២៣ ៩០០ ៥៩១ | ១០០,០% |
| +តាមអាណត្តិបើកប្រាក់ | ២៣ ៩០១ ៨០៩ | ១២ ៧០៤ ០៦៨ | | ២៣ ៩០០ ៥៩១ | |
| +តាមរជ្ជទេយ្យបុរេប្រទាន និងបុរេប្រទាន | | ៦៨៨ ៩៦៣ | | | |
| ២. ចំណាយមូលធន | ៤ ៦២៥ ០៩៦ | ២ ១៨៥ ៥០៧ | ៤៧,៣% | ៤ ៧៦៧ ៩៨៩ | ១០៣,១% |
| +តាមអាណត្តិបើកប្រាក់ | ៤ ៦២៥ ០៩៦ | ១ ៩៤៣ ៨៦៦ | | ៤ ៧៦៧ ៩៨៩ | |
| +តាមបុរេប្រទាន | | ២៤១ ៦៤១ | | | |

ក.២-ចំណាយចរន្តសរុបតាមអាណត្តិបើកប្រាក់ សម្រាប់ឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបាន ៥៣,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,៨ ពិន្ទុភាគរយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៨,៤% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ៖

-ចំណាយបន្ទុកបុគ្គលិក ដែលមានសមាមាត្រ ៤៤,៤% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបាន ៥ ២១១ ១៩៦ លានរៀល ស្មើនឹង ៤៩,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៣,៦ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៥,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយ

ជាសាច់ប្រាក់កើនចំនួន ១១,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ជារួម, ប្រាក់បៀវត្សរបស់មន្ត្រីរាជការ គឺអនុវត្តបានល្អ។

-**ចំណាយមិនមែនបន្ទុកបុគ្គលិក** ដែលមានសមាមាត្រ ៥៥,៦% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបានចំនួន ៧ ៤៩២ ៨៧២ លានរៀល ស្មើនឹង ៥៦,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងចំនួន ៥,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៥០,៦% នៃច្បាប់ហិរញ្ញវត្ថុ, ក៏ប៉ុន្តែ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៩,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។

ក.៣-ពិនិត្យមើលការអនុវត្តចំណាយចរន្តតាមវិស័យ, តាមអាណត្តិបើកប្រាក់, ឃើញថា៖

- **វិស័យរដ្ឋបាលទូទៅ** អនុវត្តបានចំនួន ១ ៦៧៤ ៤៩៩ លានរៀល ស្មើនឹង ៥១,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៧,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ១៨,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៤៦៨ ១២០ លានរៀល ស្មើនឹង ៥១,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,៥ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៦,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ១៦,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដោយសារមានការដំឡើងបៀវត្សជូនមន្ត្រីរាជការនៅឆ្នាំ ២០២៥។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបាន ១ ២០៦ ៣៧៩ លានរៀល ស្មើនឹង ៥១,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,១ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៧,៨% នៃច្បាប់ហិរញ្ញវត្ថុ។ សម្ទុះលឿននៃការអនុវត្តចំណាយនេះ គឺដោយសារមានការបន្ថែមឥណទានជូន៖ (១)-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការបើកដំណើរការស្ថានទូតថ្មី រួមមាន : ស្ថានទូតនៅប៉ាគីស្ថាន, ស្ថានទូតនៅអាប៊ីសាអ៊ូឌីត និងស្ថានអគ្គកុងស៊ុលកម្ពុជានៅសុងក្លា (ប្រទេសថៃ) (២)-ព្រឹទ្ធសភា សម្រាប់ការងារជំនួយសង្គមដល់ប្រជាពលរដ្ឋ និងការងារចុះសួរសុខទុក្ខប្រជាពលរដ្ឋរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, (៣)-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការងារចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋតាមគោលការណ៍ និងនីតិវិធីថ្មី, និង (៤)-ក្រសួងមុខងារសាធារណៈ សម្រាប់រៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌចូលបម្រើការងារតាមក្រសួង ស្ថាប័ន និងការរៀបចំដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងក្របខ័ណ្ឌនៃការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា។ ទន្ទឹមនេះ, ក៏មានការផ្ទេរឥណទាន សម្រាប់ការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០២៥ ចំនួន ១០ ប៊ីលានរៀល, កម្មវិធីផ្តល់ដីការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាពសម្រាប់ឆ្នាំ ២០២៥ ចំនួន ៦៣,៩ ប៊ីលានរៀល, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន ១២ ប៊ីលានរៀល សម្រាប់និងការសាងសង់ផ្ទះជូនគ្រួសារកងកម្លាំងប្រដាប់អាវុធ និងអតីតយុទ្ធជន ផងដែរ និងក្រសួងផែនការចំនួន ៦,២ ប៊ីលានរៀល សម្រាប់ឆ្នាំ ២០២៥ លើការអនុវត្តការងារជំរឿនសេដ្ឋកិច្ចនិងសង្គមកិច្ច, ការងារអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា និងការងារអង្កេតកម្លាំងពលកម្ម។

ជារួម, ក្រសួង ស្ថាប័ននៃវិស័យរដ្ឋបាលទូទៅ បាននិងកំពុងផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីសម្រេចសមិទ្ធកម្មគន្លឹះៗ តាមគោលដៅកំណត់ រួមមាន៖ (១)-ការអនុវត្តច្បាប់ស្តីពីវិនិយោគថ្មី, ការគាំទ្រធុរកិច្ចថ្មី, ថ្នាលឌីជីថល និងសេដ្ឋកិច្ចនវានុវត្តន៍ និងត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១», (២)-ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូល

សារពើពន្ធ, (៣)-ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, (៤)-ការគាំទ្រការកែទម្រង់វិស័យដីធ្លី, (៥)-ការសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, (៦)-ការបង្កើនប្រសិទ្ធភាពនៃកិច្ចការទូត និង (៧)-ការគាំទ្រដល់សកម្មភាពនៃអង្គភាពប្រឆាំងអំពើពុករលួយ។

- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** អនុវត្តបានចំនួន ២ ៦៦៩ ២៤២ លានរៀល ស្មើនឹង ៤៧,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ២,៣ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៥,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៨,២%។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ២ ២៦៤ ៨៥០ លានរៀល ស្មើនឹង ៤៩,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ០,៨ ពិន្ទុភាគរយ នឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៨,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៤,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ **ចំពោះចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៤០៤ ៣៩២ លានរៀល ស្មើនឹង ៣៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាងចំនួន ៨,៨ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ២៩,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៣៨,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដោយសារមានការបន្ថែមឥណទានជូន៖ (១)-ក្រសួងមហាផ្ទៃ សម្រាប់ទូទាត់កិច្ចសន្យាជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់, គោលរបបឧបត្ថម្ភជនជាប់ឃុំ, និងការរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៨០ ឆ្នាំ ២០២៥ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា, (២)-ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រការអនុវត្តវិធានការគន្លឹះ "ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌" និង (៣)-រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សម្រាប់ការអនុវត្តសកម្មភាពគាំទ្រដល់ការចុះវាស់វែងបោះបង្គោលព្រំដែនកម្ពុជា-ថៃ, កម្ពុជា-ឡាវ និងថវិកាសម្រាប់ការថែទាំមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន។

ជារួម, ក្រសួង ស្ថាប័នទាំងនៃវិស័យការពារជាតិ បាននិងកំពុងផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីសម្រេចសមិទ្ធកម្មគន្លឹះៗ តាមគោលដៅកំណត់ រួមមាន៖ (១)-ការពង្រឹងសមត្ថភាពនគរបាល និងកងកម្លាំងប្រដាប់អាវុធ, (២)-ការបន្តគាំទ្រដល់ការអនុវត្តកិច្ចការពារអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាព និងកិច្ចប្រតិបត្តិការសង្គ្រោះប្រជាពលរដ្ឋ, (៣)-ការបន្តគាំទ្រដល់ការអនុវត្តកិច្ចការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ, (៤)-ការបន្តគាំទ្រដល់ការផលិតលិខិតឆ្លងដែន និងប្រតិបត្តិការផលិតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ, (៥)-ការបន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព", (៦)-ការគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, (៧)-ការគាំទ្រដល់ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ តាមរយៈការអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, (៨)-ការបន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលា-ជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ, (៩)-ការបន្តគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី និងការពង្រឹងការគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី, (១០)-ការគាំទ្រដល់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ជាពិសេស ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសាការី, (១១)-ការបន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ និង (១២)-ការបន្តគាំទ្រសកម្មភាពការងារពាក់ព័ន្ធនឹងកិច្ចការព្រំដែន, ការចុះវាស់វែង, ថែទាំ និងបោះបង្គោលព្រំដែន។

• **វិស័យសង្គមកិច្ច** អនុវត្តបានចំនួន ៤ ៩៥១ ៧២២ លានរៀល ស្មើនឹង ៥២,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៨,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៤,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ២១,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ២ ១៨៨ ១០៧ លានរៀល ស្មើនឹង ៤៩,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៦,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤២,៥% នៃច្បាប់ហិរញ្ញវត្ថុ។ ចំពោះ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៥៥,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៩,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤៥,៥% នៃច្បាប់ហិរញ្ញវត្ថុ ដោយមានការបន្ថែមឥណទានជូន៖ (១)-ក្រសួងសុខាភិបាល សម្រាប់ការទិញឱសថព្យាបាលជំងឺទឹកនោមផ្អែម, លើសសម្ពាធឈាម និងឧបករណ៍តេស្ត, ការបន្ថែមថវិកាសម្រាប់មូលនិធិសមធម៌សុខាភិបាល លើការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃ, និងការធ្វើទំនើបកម្ម តាមរយៈការបំពាក់បរិក្ខារពេទ្យដល់មន្ទីរពេទ្យជាតិ, (២)-ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការពង្រីកវិសាលភាពនៃការផ្តល់អាហារូបករណ៍ដល់សិស្ស, ការពង្រីកចំនួនសាលារៀនគំរូ, និងការផ្តល់ថវិកាសម្រាប់កិច្ចដំណើរការពហុកីឡដ្ឋានជាតិមរតកតេជោ, (៣)-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ ក្នុងគ្រួសារក្រីក្រ, និងការតម្លើងអត្រាប្រាក់ឧបត្ថម្ភសម្រាប់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ ទន្ទឹមនេះ, ក៏មានការផ្ទេរឥណទានចំនួន ៨,២ ប៊ីលានរៀល ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ចំណាយបញ្ជូនប្រតិភូកីឡា និងសិល្បៈទៅចូលរួមប្រកួតកីឡាយុវជនអាស៊ីលើកទី ៤ ឆ្នាំ ២០២៥។

**ជារួម**, ក្រសួង ស្ថាប័ននៃវិស័យសង្គមកិច្ច បាននិងកំពុងផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីសម្រេចសមិទ្ធកម្មគន្លឹះៗ តាមគោលដៅដែលបានកំណត់ រួមមាន៖ (១)-ការលើកកម្ពស់គុណភាពអប់រំ និងការបន្តគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ ព្រមទាំងការអប់រំកាយនិងកីឡា, (២)-ការបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យការងារ និងការរក្សាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ, (៣)-ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសកល ពិសេសសម្រាប់ប្រជាជនក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ, (៤)-ការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជំនួយសង្គម, (៥)-បន្តផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន, (៦)-ការបន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន, (៧)-ការបន្តឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះ ដោយសារការប្រើប្រាស់គ្រឿងញៀន និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, (៨)-ការបន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាននិងការងារអភិរក្ស, (៩)-ការបន្តគាំទ្រដល់ការលើកកម្ពស់យេនឌ័រ, (១០)-ការគាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ, (១១)-ការការពារ និងអភិរក្សធនធានធម្មជាតិ, (១២)-ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ និង (១៣)-សុខដុមនីយកម្មសាសនា។

• **វិស័យសេដ្ឋកិច្ច** អនុវត្តបានចំនួន ៦៩៧ ២៣៩ លានរៀល ស្មើនឹង ៣៧,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន

ចំនួន ២៨,៩% នៃច្បាប់ហិរញ្ញវត្ថុ, ក៏ប៉ុន្តែ បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៣៧,៣%។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបាន ចំនួន ២៩០ ១២០ លានរៀល ស្មើនឹង ៤២,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១,៦ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបានចំនួន ៤០,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៩,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ចំពោះ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៤០៧ ១១៨ លានរៀល ស្មើនឹង ៣៥,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១៣,៤ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ២២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ៦៧,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ដោយមានការបន្ថែមឥណទានជូន៖ (១)-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សម្រាប់ចំណាយលើការទិញឧបករណ៍បច្ចេកទេស, សម្ភារៈ និងគ្រឿងបន្លាស់ឧបករណ៍ឧតុនិយម ដើម្បីបំពាក់នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ដំណាក់កាលទី ២ ឆ្នាំ ២០២៥, (២)-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការជ្រើសរើសមន្ត្រីបច្ចេកទេសកសិកម្មចំនួន ៨០០ នាក់ លើផែនការដាក់ពង្រាយឱ្យបានគ្រប់ឃុំ-សង្កាត់ សរុបចំនួន ១ ៦០០ នាក់, (៣)-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់គាំទ្រដល់ដំណើរការអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសន្តិសុខឌីជីថល (គ.ស.ឌ.) និងការគាំទ្របន្ថែមជូនគណៈកម្មការរដ្ឋាភិបាលឌីជីថល, និង (៤)-ក្រសួងទេសចរណ៍ សម្រាប់ការផ្តល់ថវិកាដល់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB)។ ទន្ទឹមនេះ ក៏មានការផ្ទេរឥណទានចំនួន ២១,៩ ប៊ីលានរៀល ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សម្រាប់ចំណាយទិញឧបករណ៍បច្ចេកទេស សម្ភារៈបរិក្ខារ និងគ្រឿងបន្លាស់ឧបករណ៍ឧតុនិយម សម្រាប់បំពាក់នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដំណាក់កាលទី ១ ក្នុងឆ្នាំ ២០២៥ និងការផ្ទេរឥណទានចំនួន ២,៩ ប៊ីលានរៀល ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ចំណាយបោះបង្គោលព្រំការពារដីតំបន់កាត់ឆ្មៀល (តំបន់ ១ និងតំបន់ ២ ស្ថិតក្នុងតំបន់ ៣) នៅភូមិសាស្ត្រខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ។

**ជារួម**, ក្រសួង ស្ថាប័ននៃវិស័យសេដ្ឋកិច្ច បាន និងកំពុងផ្តោតលើការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីសម្រេចសមិទ្ធកម្មគន្លឹះៗ តាមគោលដៅដែលបានកំណត់ រួមមាន៖ (១)-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ, (២)-ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស, (៣)-ការបន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម និងសុវត្ថិភាពចំណីអាហារ, (៤)-ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល, (៥)-ការបង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ, (៦)-ការជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ, (៧)-ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ, (៨)-ការជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍, (៩)-ការបន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា, (១០)-ការបន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត, (១១)-ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ, (១២)-ការអភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក, (១៣)-ការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និង (១៤)-ការអភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

*ដូចនេះ, បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤, ក្នុងពេល ៦ ខែដើមឆ្នាំ ២០២៥ នេះ, ការអនុវត្តចំណាយនៃវិស័យរដ្ឋបាលទូទៅ, វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ, វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច មានសម្ទុះលឿនជាង ដោយសារ, ម៉្យាង, ក្រសួង ស្ថាប័នបានយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការអនុវត្តថវិកាសមិទ្ធកម្ម និងម៉្យាងទៀត, មានការបន្ថែមឥណទានពី**ឥណទានចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល** ជូនដល់ក្រសួង ស្ថាប័នមួយចំនួន សម្រាប់អនុវត្តកម្មវិធីគោលនយោបាយអាទិភាព និងវិធានការគន្លឹះ ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញ ដូចបានរៀបរាប់នៅតាមវិស័យនីមួយៗខាងលើ។*

ក.៤-**ចំណាយមូលធនឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ** សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០២៥ តាមអាណត្តិបើកប្រាក់អនុវត្តបាន ៤២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៣ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៣៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើន ១១,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ **ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាជាតិ** អនុវត្តបានចំនួន ៦៥៩ ២៩៧ លានរៀល ស្មើនឹង ២៥,៥% នៃច្បាប់ហិរញ្ញវត្ថុ, មានសម្ទុះយឺតជាង ១,៧ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ២៧,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយ ៣៥,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ បើគិតទាំងបុរេប្រទាន, ចំណាយមូលធនអនុវត្តបាន ៤៧,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៨,៣ ពិន្ទុភាគរយធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៣៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើន ២៤,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ចំពោះ**ចំណាយមូលនិធិទ្រទ្រង់ថវិកា** អនុវត្តឆមាសទី ១ បានចំនួន ១ ២៨៤ ៥៦៩ លានរៀល ស្មើនឹង ៦៣,១% នៃច្បាប់ហិរញ្ញវត្ថុ។ ជារួម, **តាមការព្យាកររហូតដល់ចុងឆ្នាំ, ចំណាយមូលធនដោយថវិកាជាតិឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិអាចនឹងសម្រេចបានប្រមាណ ១០៣,១% នៃច្បាប់ហិរញ្ញវត្ថុ**។ ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសនឹងជម្រាបជូនក្នុងផ្នែក ៣.២.៤ ខាងក្រោម ព្រោះស្ថានភាពចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ជាគោលការណ៍ គឺស្មើនឹងចំណូលវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ហើយជាប្រភេទចំណូល-ចំណាយប្រតិបត្តិការក្រៅប្រព័ន្ធរតនាគារជាតិ។

### ខ-ចំណាយថ្នាក់ក្រោមជាតិ

ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបានចំនួន ១ ៥០៣ ៧៤៤ លានរៀល ស្មើនឹង ៣៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៤,៤ ពិន្ទុភាគរយធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ២៩,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើន ១៧,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ក្នុងនោះចំណាយចរន្តអនុវត្តបានចំនួន ១ ៤៨១ ៦៤១ លានរៀល ស្មើនឹង ៣៦,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៣,៦ ពិន្ទុភាគរយធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ ដែលអនុវត្តបាន ៣៣,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនចំនួន ១៧,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤ (បន្ទុកបុគ្គលិកអនុវត្តបានចំនួន ៣៩៥ ១១៤ លានរៀល ស្មើនឹង ៤៣,៨% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណាយជាសាច់ប្រាក់កើន ៩,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤) និងចំណាយមូលធន អនុវត្តបានចំនួន ២២ ១០៣ លានរៀល ស្មើនឹង ៥,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ១,២ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុង

ឆ្នាំ ២០២៤ ដែលអនុវត្តបាន ៤,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយ ៤,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ជារួម ការអនុវត្តចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិឆមាសទី ១ មានសម្ទុះលឿនដោយសារសមតុល្យសាច់ប្រាក់នៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ ជាពិសេសប្រភពចំណូលធំៗត្រូវទទួលបាននៅត្រីមាសទី ៣ និងទី ៤ នៃឆ្នាំអនុវត្តថវិកា។ តាមការព្យាករណ៍រហូតដល់ដំណាច់ឆ្នាំ, ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងអាចទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៧,៥% ដោយសារចំណូលពន្ធដារថ្នាក់ក្រោមជាតិ អាចនឹងអនុវត្តទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១៥,១%។

ឯកតា៖ លានរៀល

**តារាងទី ៦៖ តារាងចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

| ប្រតិបត្តិការ | ឆ្នាំ ២០២៥ | | | | |
|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តឆមាសទី ១ | | ប៉ាន់ស្មានប្រចាំឆ្នាំ | |
| | | ទឹកប្រាក់ | %ច្បាប់ | ទឹកប្រាក់ | %ច្បាប់ |
| **សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ** | ៤ ៤២១ ៥៨០ | ១ ៥០៣ ៧៤៤ | ៣៤,០% | ៤ ០៨៨ ៣២៩ | ៩២,៥% |
| សរុបចំណាយចរន្ត | ៤ ០២១ ៥៨០ | ១ ៤៨១ ៦៤១ | ៣៦,៨% | ៣ ៦៨៨ ៣២៩ | ៩១,៧% |
| -បន្ទុកបុគ្គលិក | ៩០២ ០៦១ | ៣៩៥ ១១៤ | ៤៣,៨% | ៩០២ ០៦១ | ១០០,០% |
| -មិនមែនបន្ទុកបុគ្គលិក | ៣ ១១៩ ៥១៩ | ១ ០៨៦ ៥២៧ | ៣៤,៨% | ២ ៧៨៦ ២៦៨ | ៨៩,៣% |
| សរុបចំណាយមូលធន | ៤០០ ០០០ | ២២ ១០៣ | ៥,៥% | ៤០០ ០០០ | ១០០,០% |
| **ក-ចំណាយថវិការាជធានី ខេត្ត** | ២ ៥៣៦ ២០៧ | ៦៥៩ ៧៦៨ | ២៦,០% | ២ ២០២ ៣៨០ | ៨៦,៨% |
| សរុបចំណាយចរន្ត | ២ ១៣៦ ២០៧ | ៦៣៧ ៦៦៥ | ២៩,៩% | ១ ៨០២ ៣៨០ | ៨៤,៤% |
| -បន្ទុកបុគ្គលិក | ២១៦ ២៦១ | ៥៩ ៦៨២ | ២៧,៦% | ២១៦ ២៦១ | ១០០,០% |
| -មិនមែនបន្ទុកបុគ្គលិក | ១ ៩១៩ ៩៤៦ | ៥៧៧ ៩៨៣ | ៣០,១% | ១ ៥៨៦ ១១៩ | ៨២,៦% |
| សរុបចំណាយមូលធន | ៤០០ ០០០ | ២២ ១០៣ | ៥,៥% | ៤០០ ០០០ | ១០០,០% |
| **ខ-ចំណាយថវិកាក្រុង ស្រុក** | ៥៨៧ ៧៣១ | ១៩៥ ១៥៦ | ៣៣,២% | ៥៨៧ ៧៣១ | ១០០,០% |
| សរុបចំណាយចរន្ត | ៥៨៧ ៧៣១ | ១៩៥ ១៥៦ | ៣៣,២% | ៥៨៧ ៧៣១ | ១០០,០% |
| -បន្ទុកបុគ្គលិក | ២៧២ ០៦៧ | ១២៨ ៥៦៦ | ៤៧,៣% | ២៧២ ០៦៧ | ១០០,០% |
| -មិនមែនបន្ទុកបុគ្គលិក | ៣១៥ ៦៦៤ | ៦៦ ៥៩០ | ២១,១% | ៣១៥ ៦៦៤ | ១០០,០% |
| **គ-ចំណាយថវិកាឃុំ សង្កាត់** | ១ ២៩៧ ៦៤២ | ៦៤៨ ៨២០ | ៥០,០% | ១ ២៩៨ ២១៨ | ១០០,០% |
| សរុបចំណាយចរន្ត | ១ ២៩៧ ៦៤២ | ៦៤៨ ៨២០ | ៥០,០% | ១ ២៩៨ ២១៨ | ១០០,០% |
| -បន្ទុកបុគ្គលិក | ៤១៣ ៧៣៣ | ២០៦ ៨៦៦ | ៥០,០% | ៤១៣ ៧៣៣ | ១០០,០% |
| -មិនមែនបន្ទុកបុគ្គលិក | ៨៨៣ ៩០៩ | ៤៤១ ៩៥៤ | ៥០,០% | ៨៨៤ ៤៨៥ | ១០០,០% |

## ៤.៤- ហិរញ្ញប្បទានសហប្រតិបត្តិការ

### ក-ការដកសាច់ប្រាក់

ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ មានឥណទានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសចំនួន ៦ ៨៧១ ២៧០ លានរៀល។ ជាក់ស្តែង, ការដកសាច់ប្រាក់យកមកប្រើប្រាស់ក្នុងគម្រោង/កម្មវិធីអភិវឌ្ឍន៍ នៅក្នុងឆមាសទី ១ ឆ្នាំ ២០២៥ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងឥណទានសម្បទាន និងកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង តាមបរិបថរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានសរុបប្រមាណ ៤៤៥,០៧ លានដុល្លារអាម៉េរិក ឬសមមូលនឹង ១ ៧៩៣,២៦ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ២៦,១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ៖ ឥណទានសម្បទានសម្រេចបានចំនួន ៤០៨,៩៨ លានដុល្លារអាម៉េរិក ឬសមមូលនឹង ១ ៦៤៨,៥១ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ២៦,១៤% នៃឥណទានប្រចាំឆ្នាំ; ចំណែកហិរញ្ញប្បទានឥតសំណង សម្រេចបានចំនួន ៣៦,០៨ លានដុល្លារអាម៉េរិក ឬសមមូលនឹង ១៤៤,៧៦ ប៊ីលានរៀល គឺស្មើនឹងប្រមាណ ៤២,៦៤% នៃឥណទានប្រចាំឆ្នាំ។ ទឹកប្រាក់នេះ នៅមិនទាន់បញ្ចូលនៅឡើយនូវហិរញ្ញប្បទានឥតសំណងមួយចំនួនទៀត ដែលត្រូវបានផ្តល់ទៅដល់គោលដៅអនុវត្តផ្ទាល់ដោយដៃគូអភិវឌ្ឍន៍តែម្តង ដោយមិនឆ្លងតាមបរិបថ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរួមទាំងគម្រោងវិនិយោគផ្ទាល់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម និងគម្រោងកសាងសមត្ថភាពផងដែរ។

### ខ-ការចុះកិច្ចព្រមព្រៀងថ្មី

ក្នុងឆមាសទី ១ នៃ ឆ្នាំ ២០២៥ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន មានទឹកប្រាក់សរុបចំនួនប្រមាណ ២៦៦,២២ លានដុល្លារអាម៉េរិក សម្រាប់អនុវត្ត ១០ គម្រោង/កម្មវិធីអភិវឌ្ឍន៍ ដែលក្នុងនោះមាន៖

-ហិរញ្ញប្បទានឥតសំណងចំនួន ៧ គម្រោង/កម្មវិធី មានទឹកប្រាក់សរុបចំនួនប្រមាណ ៦៩,៧៤ លានដុល្លារអាម៉េរិក។ ទឹកប្រាក់នេះ មិនរាប់បញ្ចូលទឹកប្រាក់ហិរញ្ញប្បទាន ដែលដៃគូអភិវឌ្ឍន៍បានផ្តល់ទៅដល់បណ្តាគោលដៅអនុវត្តដោយផ្ទាល់ដោយមិនឆ្លងកាត់រាជរដ្ឋាភិបាលទេ។

-ឥណទានសម្បទានចំនួន ៣ គម្រោង/កម្មវិធី មានទឹកប្រាក់សរុបចំនួនប្រមាណ ១៩៦,៤៨ លានដុល្លារអាម៉េរិក ឬប្រមាណ ១៤២,៣១ លានអេសដេអែរ គឺស្មើនឹងប្រមាណ ៧,១២% នៃច្បាប់ហិរញ្ញវត្ថុ។

## ៤.៥- ការប៉ាន់ស្មាន និងការវាយតម្លៃលើការអនុវត្តចំណាយឆ្នាំ ២០២៥

ជាមួយនឹងការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយប្រសិទ្ធភាពខ្ពស់, ចំណាយបន្ទុកបុគ្គលិក ជាពិសេសបៀវត្ស ត្រូវបានប៉ាន់ស្មានថានឹងអនុវត្តស្មើនឹងច្បាប់ហិរញ្ញវត្ថុ ហើយអាចឆ្លើយតបបានទៅនឹងគោលនយោបាយដំឡើងបៀវត្សឆ្នាំ ២០២៥ របស់រាជរដ្ឋាភិបាល។ ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ត្រូវបានដំឡើងតាមផែនការដែលបានគ្រោងទុក។ ជាក់ស្តែង, បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិលទូទៅ កើនដល់ចំនួន ១ ៣៩៦ ៩៥០ រៀល, បៀវត្សអប្បបរមាគ្រូបង្រៀន និងគ្រូពេទ្យ កើនដល់ចំនួន ១ ៤៩៦ ៩៥០ រៀល, បៀវត្សអប្បបរមានគរបាលជាតិ (ពលបាលត្រី) កើនដល់ចំនួន ១ ៤៨៣ ៩២៧ រៀល (ដោយគិតបញ្ចូលទាំងរបបអង្ករ) និងបៀវត្សអប្បបរមាយោធិន (ពលទោ) កើនដល់ចំនួន ១ ៤០៥ ០២៧

រៀល (ដោយគិតបញ្ចូលទាំងរបបអង្គរ)។ ចំពោះប្រាក់បំណាច់របស់ មន្ត្រីជាប់កិច្ចសន្យា ក៏ត្រូវបានដំឡើងដល់ចំនួន **៧៩ ម៉ឺនរៀល**ផងដែរ។ ទន្ទឹមនេះ, មន្ត្រីរាជការទូទៅ ក៏ដូចជានិវត្តជនជាអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ក៏ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ ៥ ម៉ឺនរៀល សម្រាប់ការចូលឆ្នាំប្រពៃណីខ្មែរ និង ៥ ម៉ឺនរៀលសម្រាប់បុណ្យភ្ជុំបិណ្ឌ។ ជាមួយគ្នានេះដែរ, ប្រាក់របបសន្តិសុខសង្គមប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ក៏ត្រូវបានដំឡើងដល់ចំនួន **៨៤,៥ ម៉ឺនរៀល** ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់និវត្តជន។ លើសពីនេះ, រាជរដ្ឋាភិបាល ក៏បានផ្តល់ថវិកាសម្រាប់ការអនុវត្តការថែទាំសុខភាពមន្ត្រីសាធារណៈ, អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីរ៉ាប់រងលើការទ្រទ្រង់ថែទាំសុខភាពមន្ត្រីសាធារណៈ បន្ថែមពីលើប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួនពីរ គឺប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី និងប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការដែលទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណី ដែលត្រូវបានដាក់ឱ្យអនុវត្តរួចមកហើយ និងសម្រាប់កញ្ចប់ថវិកាទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ។ ចំណែកឯ, **ចំណាយមិនមែនបន្ទុកបុគ្គលិក** របស់ក្រសួង ស្ថាប័ន ក្នុងឆមាសទី ២ ខាងមុខ អាចនឹងមានសន្ទុះលឿនជាងនៅក្នុងឆមាសទី ១ ហើយនឹងត្រូវតម្រង់ការអនុវត្តចំណាយឱ្យចំទិសដៅ តាមរយៈការពង្រឹងប្រសិទ្ធភាពប្រតិបត្តិចំណាយ និងការដាក់ចេញវិធានការចាំបាច់មួយចំនួន។

ជារួម, ផ្អែកលើលទ្ធផលអនុវត្តក្នុងឆមាសទី ១ និងនិន្នាការចំណាយនៅឆមាសទី ២ អាចសន្និដ្ឋានបានថា **ការអនុវត្តចំណាយឆ្នាំ ២០២៥ នឹងទាបជាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ក្នុងរង្វង់ប្រមាណ 0,៥%**។ ទោះជាយ៉ាងនេះក្តី, ជាមួយនឹងការវាយតម្លៃអំពីទិដ្ឋភាពនៃការអនុវត្តចំណាយថវិកា ដូចបានរៀបរាប់ខាងលើ និងរហូតដល់ដំណាច់ឆ្នាំ, ផ្នែកចំណាយអាចជួបប្រទះបញ្ហាប្រឈមខាងបច្ចេកទេសមួយចំនួនដូចខាងក្រោម៖

**-ចំណាយចរន្ត**

- ចំណាយខ្លះមិនទាន់មានប្រសិទ្ធភាពខ្ពស់ ពិសេសនៅកម្រិតប្រតិបត្តិការ (ប្រសិទ្ធភាពបច្ចេកទេស និងតម្លៃនៃលុយ) ទោះបីជាមានការកែលម្អច្រើនហើយក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- បញ្ហាសមត្ថភាព និងការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ រដ្ឋទេយ្យករបុរេប្រទាន មន្ត្រីទទួលបន្ទុកចុះប្រតិបត្តិការក្នុង FMIS និងក្រុមលទ្ធកម្ម នៅតែបន្តកើតមាននៅតាមក្រសួង ស្ថាប័ន,
- ក្រោយទទួលបានធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័នខ្លះ ចាប់ផ្តើមអនុវត្តកិច្ចលទ្ធកម្មយឺត មិនស្របតាមពេលដែលបានកំណត់ក្នុងផែនការលទ្ធកម្ម គួបផ្សំនឹងបញ្ហាសមត្ថភាពមន្ត្រីលើការងារលទ្ធកម្មសាធារណៈ,
- បញ្ហាបច្ចេកទេសក្នុងប្រព័ន្ធ FMIS ត្រូវបានដោះស្រាយបន្តបន្ទាប់ ប៉ុន្តែនៅមានភាពចាំបាច់ត្រូវបន្តកែលម្អ ដើម្បីសម្រួលដល់ការប្រើប្រាស់ (Friendly use) នៅក្នុងការអនុវត្តថវិកា,
- ក្រសួង ស្ថាប័នភាគច្រើន នៅមិនទាន់ប្រគល់ប្រសិទ្ធអំណាចដល់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញនៅក្នុងប្រតិបត្តិការចំណាយ ស្របតាមបទដ្ឋានគតិយុត្ត។

-ចំណាយវិនិយោគ

- គម្រោងវិនិយោគផ្ទាល់ មិនមានកំណើន ឬត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ចាប់ពីក្រោយវិបត្តិជំងឺកូវីដ-១៩ ដែលការណ៍នេះ កំពុងដាក់សម្ពាធកាន់តែខ្លាំងដល់លទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយតម្រូវការអភិវឌ្ឍន៍ជាមូលដ្ឋាន (ជាការបំពេញគ្នាជាមួយសមិទ្ធផលធំៗទាំងឡាយ ក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ) ក៏ដូចជាការដោះស្រាយសំណូមពរចាំបាច់ប្រចាំថ្ងៃរបស់ប្រជាជន ដែលមានបច្ច័យយ៉ាងសំខាន់ខាងសង្គម សេដ្ឋកិច្ច និងនយោបាយ,
- រាជរដ្ឋាភិបាលមានតម្រូវការអនុវត្តគម្រោងថ្មីធំៗមួយចំនួន ដែលមានសារៈសំខាន់ខាងនយោបាយ និងសង្គម ដែលការណ៍នេះដាក់សម្ពាធបន្ថែមទៅលើឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ ដោយសារគម្រោងធំៗទាំងនោះ មានតម្រូវការទូទាត់ពហុឆ្នាំ ហើយជាយថាហេតុ អាចបង្កើនបន្ទុកបំណុល ព្រមទាំងនាំឱ្យប៉ះពាល់ដល់គម្រោងមួយចំនួនដែលបានគ្រោងរួចហើយ,
- ការវិនិយោគថ្មីដោយហិរញ្ញប្បទានសហប្រតិបត្តិការលើវិស័យហេដ្ឋារចនាសម្ព័ន្ធ មានសម្ទុះលឿន ដែលការណ៍នេះកំពុងដាក់សម្ពាធបន្ថែមលើចំណាយថវិកា ទាំងក្នុងក្របខ័ណ្ឌកញ្ចប់ថវិកាគម្រោងវិនិយោគផ្ទាល់ ទាំងថវិកាជួសជុល និងថែទាំ ព្រោះការបន្តថែទាំ និងជួសជុល ជាកាតព្វកិច្ចរបស់រដ្ឋ,
- ដោយសារលទ្ធភាពថវិកាមានកំណត់ ការពុះប្រៀកគម្រោងអនុវត្តជាច្រើនឆ្នាំ ក៏បានធ្វើឱ្យតម្លៃគម្រោងកើន និងទទួលបានសមិទ្ធផលយឺត,
- ការកត់ត្រាថវិកាបុរេប្រទានជាចំណាយក្នុងឆ្នាំ ២០២៥ បានធ្វើឱ្យមានតម្រូវការឥណទានថវិកាច្រើនជាងឆ្នាំមុនៗ នៅតាមក្រសួង ស្ថាប័ន ដែលតម្រូវឱ្យដកប្រើកញ្ចប់ឥណទានថវិកាត្រៀមបម្រុងរបស់រាជរដ្ឋាភិបាល ដែលបានគ្រោងសម្រាប់ដោះស្រាយតម្រូវការអាទិភាពផ្សេងទៀត,
- សមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ នៅមានកម្រិត។

## ៤.៦- តុល្យភាពចំណូល-ចំណាយឆមាសទី ១ និងការវាយតម្លៃការអនុវត្តថវិកាឆ្នាំ ២០២៥

ជារួម, ចំណូលថវិកាថ្នាក់ជាតិឆមាសទី ១ ឆ្នាំ ២០២៥ អនុវត្តបាន ៥៣,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានសម្ទុះលឿនជាង ៧,៩ ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៤។ ចំណែកឯផ្នែកចំណាយថវិកាថ្នាក់ជាតិវិញ, មានសម្ទុះលឿនជាងឆ្នាំ ២០២៤ ពោលគឺសម្រេចបាន ៥៤,៦% (គិតទាំងបុរេប្រទាន) នៃច្បាប់ហិរញ្ញវត្ថុ។ តាមការប៉ាន់ស្មានដល់ដំណាច់ឆ្នាំ, ឱនភាពថវិកាសរុបឆ្នាំ ២០២៥ នឹងមានទំហំ -៧ ១៩៨ ១៩៤ លានរៀល សមមូលនឹងប្រមាណ ១ ៧៧៦ លានដុល្លារអាម៉េរិក, ត្រូវជា -៣,៥០% នៃ ផ.ស.ស. គឺខ្ពស់ជាងឱនភាពថវិការដ្ឋសរុបដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ស្មើនឹង -៣,០៩% នៃ ផ.ស.ស.។ ក្នុងស្ថានភាពនេះ, បន្ថែមលើទំហំហិរញ្ញប្បទានដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥, រាជរដ្ឋាភិបាលអាចនឹងមានការចាំបាច់ត្រូវប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាលក្នុងទំហំប្រមាណ ៨៤៥ ៨៨២ លានរៀល សមមូលនឹងប្រមាណ ២០៩ លានដុល្លារអាម៉េរិក ដើម្បីបំពេញតម្រូវការចំណាយតាមការគ្រោងទុក ក៏ដូចជាដើម្បីរក្សាតុល្យភាពថវិកាឆ្នាំ ២០២៥។ ក្នុងន័យនេះ, ការខកខានក្នុងការសម្រេចបាននូវលទ្ធផលចំណូលតាមការប៉ាន់ស្មានដល់ដំណាច់ឆ្នាំ ក៏ដូចជាការបោះផ្សាយលក់មូលបត្ររដ្ឋមិនបានគ្រប់ផែនការឆ្នាំ ២០២៥ នឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានថែមទៀតដល់តុល្យភាពដែលបានព្យាករណ៍នេះ។ ផ្ទុយទៅវិញ, ប្រសិនបើការអនុវត្ត

ការប្រមូលចំណូល, ជាពិសេស ចំណូលពន្ធ និងអាករគយ ព្រមទាំងចំណូលពន្ធដារ សម្រេចបានលទ្ធផលប្រសើរជាងការប៉ាន់ស្មាននេះ, នោះរាជរដ្ឋាភិបាលអាចរក្សាបាននូវគោលការណ៍មិនប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ដូចបានគ្រោងទុកនៅពេលរៀបចំច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ស្របតាមគោលការណ៍ពង្រឹងប្រសិទ្ធភាពចំណាយជាជំហានរបស់រាជរដ្ឋាភិបាល។

**តារាងទី ៧៖ តារាងតុល្យភាពថវិការដ្ឋ**

| សូចនាករ | ២០២៣ | ២០២៤ | | ២០២៥ | |
|---|---|---|---|---|---|
| | អនុវត្ត | ច្បាប់ | អនុវត្ត | ច្បាប់ | ប៉ាន់ស្មាន |
| ផសស (លានរៀល) | ១៧៧ ៣៥១ ៤៧១ | ១៩១ ៨៦២ ៣៩៩ | | ២០៥ ៧៧៩ ៦០១ (**) | |
| I. សរុបចំណូលថវិការដ្ឋ (%ផសស) | ១៩,៨៤% | ១៦,៩៤% | ១៥,០០% | ១៥,៣៦% | ១៤,៨៥% |
| ចំណូលក្នុងប្រទេស (%ផសស) | ១៥,៤៨% | ១៦,៥៨% | ១៤,៨៣% | ១៥,០៥% | ១៤,៥៤% |
| *- ចំណូលចរន្ត (%ផសស)* | ១៥,២៤% | *១៦,៣២%* | *១៤,៥៨%* | ១៤,៧៧% | ១៤,២៥% |
| II. ចំណាយសរុបថវិការដ្ឋ (%ផសស) | ២១,០៩% | ១៩,៣៤% | ១៧,៤៦% | ១៨,៤៤% | ១៨,៣៥% |
| *- ចំណាយចរន្ត (%ផសស)* | ១៣,០០% | *១៣,៤៩%* | *១២,២៨%* | ១២,៦៦% | ១២,៥០% |
| អតិរេកចរន្ត (%ផសស) | ២,២៥% | ២,៨៣% | ២,៣០% | ២,១១% | ១,៧៦% |
| III. ឱនភាពសរុប (%ផសស) | -៥,៦១% | -២,៤០% | -២,៤៦% | -៣,០៩% | -៣,៥០% |
| IV. តម្រូវការហិរញ្ញប្បទាន | | ៣,៥០% | ៣,៣៨% | ៤,២៧% | ៤,៦៨% |
| - ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ | | ២,៤០% | ២,៤៦% | ៣,០៩% | ៣,៥០% |
| - ការទូទាត់ការខ្ចី | | ១,១០% | ០,៩២% | ១,១៨% | ១,១៨% |
| V. ប្រភពហិរញ្ញប្បទាន | | ៣,៥០% | ៣,៣៨% | ៤,២៧% | ៤,៦៨% |
| - ហិរញ្ញប្បទានក្រៅប្រទេស | | ៣,២៧% | ៣,៤៧% | ៤,០២% | ៤,០២% |
| • មូលនិធិទ្រទ្រង់ថវិកា | | ០,៣៦% | ០,៧០% | ០,៩៦% | ០,៩៦% |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | ២,៩១% | ២,៧៧% | ៣,០៦% | ៣,០៦% |
| - ហិរញ្ញប្បទានក្នុងប្រទេស | | ០,២៣% | -០,០៩% | ០,២៤% | ០,៦៥% |
| • ប្រាក់បញ្ញើរាជរដ្ឋាភិបាល | | | -០,២៥% | | ០,៤១% |
| • ការបោះផ្សាយមូលបត្ររដ្ឋ | | ០,២៣% | ០,១៦% | ០,២៤% | ០,២៤% |

*<u>សេចក្តីបញ្ជាក់៖</u> (**) ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ផ្អែកលើការវាយតម្លៃសេដ្ឋកិច្ចឡើងវិញ (ខែ កក្កដា ឆ្នាំ ២០២៥)*

## ៥- វិធានការដោះស្រាយសម្រាប់ការអនុវត្តថវិកាឆ្នាំ ២០២៥

ក្នុងគោលបំណងរក្សាតុល្យភាពថវិកា ដោយកាត់បន្ថយការប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាលឱ្យតិចជាងទំហំ ២០៩ លានដុល្លារអាមេរិក ដូចតាមការប៉ាន់ស្មានខាងលើ ក៏ដូចជាដើម្បីបង្ហាញនូវការខិតខំរបស់

រាជរដ្ឋាភិបាលក្នុងការរក្សាគោលការណ៍មិនប្រើប្រាស់ប្រាក់សន្សំ ដូចបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវវិធានការអនុវត្តចាំបាច់នានា ទាំងផ្នែកចំណូល និងទាំងផ្នែកចំណាយ ដូចខាងក្រោម៖

## ៥.១- វិធានការអនុវត្តបន្តលើការប្រមូលចំណូលសម្រាប់ឆមាសទី ២ ឆ្នាំ ២០២៥

ដើម្បីជានាសម្រេចបាននូវការប្រមូលចំណូលដូចដែលបានរំពឹងទុក ក៏ដូចជាសម្រេចបានលទ្ធផលកាន់តែប្រសើរ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តយកចិត្តទុកដាក់អនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវវិធានការក្នុងការប្រមូលចំណូល ដូចតទៅ៖

-<u>ផ្នែកពន្ធដារ</u>

វិធានការពង្រឹងការកៀរគរចំណូលពន្ធដារ មានដូចខាងក្រោម៖

- បន្តពង្រឹងអនុវត្តយន្តការការគ្រប់គ្រងសហគ្រាសផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរាដើម្បីជំរុញលើកកម្ពស់ការប្រកួតប្រជែងស្មើភាព និងពង្រឹងការធ្វើសវនកម្មលើសហគ្រាសដែលមានហានិភ័យខ្ពស់,
- បន្តពង្រឹងអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូលពីវិស័យទូរគមនាគមន៍ តាមរយៈការពង្រឹងកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការទទួលបានទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (DMC) ដើម្បីពិនិត្យអំពីកម្រិតអនុលោមភាពសារពើពន្ធរបស់សហគ្រាសក្នុងវិស័យនេះ,
- បន្តយកចិត្តទុកដាក់អនុវត្តការអនុគ្រោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យសម្រាប់ផ្ទះតម្លៃក្រោម ឬស្មើ ៧ ម៉ឺនដុល្លារអាមេរិក និងសម្រាប់អ្នកទិញលំនៅដ្ឋាន និង/ឬផ្ទេរកម្មសិទ្ធិជាលើកដំបូង (First-Time Home Buyer) តម្លៃក្រោម ឬស្មើ ២១ ម៉ឺនដុល្លារអាម៉េរិក ដល់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅដ្ឋានជាសមាជិកនៃសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជាដែលទទួលបានការលើកលែង,
- ពង្រឹងការផ្សព្វផ្សាយការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់គម្រោងជាប់គាំងក្នុងខេត្តព្រះសីហនុឱ្យកាន់តែទូលំទូលាយដើម្បីឱ្យសាធារណជនបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅ និងបន្តយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនានា,
- ពង្រឹងការទារបំណុលពន្ធ និងអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះបំណុលពន្ធដែលជាអាទិភាពអាចប្រមូលបាន តាមរយៈការជ្រើសរើសបំណុលពន្ធដែលមានសក្តានុពល ជាពិសេសបំណុលរបស់អ្នកជាប់ពន្ធធំនិងអ្នកជាប់ពន្ធមធ្យមដែលមានបំណុលពន្ធចំនួនច្រើន និងមានអាយុកាលក្រោម ៣ ឆ្នាំ ព្រមទាំងជំរុញនិងលើកទឹកចិត្តចំពោះសហគ្រាសដែលមានបំណងដោះស្រាយបំណុលពន្ធ,
- ពង្រឹង និងជំរុញការបញ្ចប់កម្មវិធីសវនកម្មដែលនៅសេសសល់ តាមរយៈការជំរុញ និងលើកទឹកចិត្តសហគ្រាសដែលមានបំណងដោះស្រាយបញ្ហាសវនកម្ម,
- ពង្រឹងយន្តការសវនកម្មពន្ធដារ តាមរយៈការអនុវត្តឱ្យខាងតែបាននូវគោលការណ៍ដូចមានកំណត់ក្នុងសៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ ការអនុវត្តវិធានការដាក់ទោសទណ្ឌចំពោះមន្ត្រីដែលប្រព្រឹត្តខុស និងយន្តការរាយការណ៍និងប្ដឹង,

• ពង្រឹងការត្រួតពិនិត្យ និងការធ្វើសវនកម្មចំពោះសហគ្រាសក្នុងវិស័យដែលមានសក្តានុពល និងមានហានិភ័យខ្ពស់ ដូចជា៖ វិស័យទូរគមនាគមន៍ អាជីវកម្មរ៉ែ និងការដឹកជញ្ជូនទំនិញ,

• ជំរុញការប្រមូលចំណូលពីវិស័យល្បែងពាណិជ្ជកម្ម ( កាស៊ីណូ ),

• បន្តរិះរកយន្តការដើម្បីផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែសាមញ្ញ រហ័ស ងាយស្រួល និងគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈឌីជីថល និងអនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិ,

• ជំរុញការរៀបចំយន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងការកំណត់អត្តសញ្ញាណអចលនទ្រព្យ ( Property ID ) សម្រាប់អចលនទ្រព្យគម្រោងបុរី,

• អនុវត្តពន្ធលើចំណេញមូលធនលើទ្រព្យ ៥ ប្រភេទ រួមមាន៖ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយវត្ថុបរទេស។

-<u>ផ្នែកចំណូលពន្ធ និងអាករគយ</u>

វិធានការពង្រឹងការកៀរគរចំណូលពន្ធ និងអាករគយ មានដូចខាងក្រោម៖

• បន្តធ្វើទំនើកម្មលើការងារស្នូលរបស់ខ្លួនឱ្យកាន់ប្រសើរឡើងបន្ថែមទៀត ជាពិសេសលើការងារទំនើបកម្មរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម,

• ពង្រីកវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,

• ពង្រឹងប្រសិទ្ធភាពអនុលោមភាពលើមុខទំនិញជាសក្តានុពលនៃការប្រមូលចំណូល រួមមាន គ្រឿងអេឡិចត្រូនីក, ស្រា, ប្រេងរំអិល ជាដើម ដោយកំណត់នូវមុខសញ្ញាដែលត្រូវត្រួតពិនិត្យរូបវន្តនៅដើមទី កណ្តាលទី និងចុងទី,

• បន្តជំរុញអនុលោមភាពដោយស្ម័គ្រចិត្តរបស់ធុរជន និងយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងទំនិញល្មើសកម្មសិទ្ធិបញ្ញា,

• ពង្រឹងការគ្រប់គ្រងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធនិងអាករក្រោមក្របខ័ណ្ឌផ្សេងៗ ពិសេសគម្រោង QIP,

• បន្តពង្រីកយន្តការធុរជនល្អនិងកម្មវិធី AEO និងពង្រឹងយន្តការភាពជាដៃគូគយ-ផ្នែកឯកជន។

-<u>ផ្នែកចំណូលមិនមែនសារពើពន្ធ</u>

វិធានការពង្រឹងការកៀរគរចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម៖

• បន្តអនុវត្តឱ្យបានគត់មត់នូវវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំផែនការទាក់ទាញទេសចរមកកាន់ខេត្តសៀមរាប ដោយទម្លាក់តម្លៃសេវាសាធារណៈមួយចំនួន ដូចជាការបង់ថ្លៃសួយសារដើម្បីលើកទឹកចិត្តដល់វិស័យបំរើសេវាទេសចណ៍,

• បន្តពង្រឹង និងជំរុញការគ្រប់គ្រងការប្រមូលចំណូលពីវិស័យទេសចរណ៍ លើការទូទាត់ប្រាក់ជាទម្រង់អេឡិចត្រូនិក ជាពិសេសការទិញប័ណ្ណចូលទស្សនារមណីដ្ឋានអង្គរ ដោយកែសម្រួលប្រព័ន្ធត្រួតពិនិត្យដែលមានភាពសាំញ៉ាំ មកជាប្រព័ន្ធមានភាពងាយស្រួល ប្រើ Self-Service Machine និងបង្កើត Mobile app,

• បន្តពង្រឹងយន្តការ និងប្រសិទ្ធភាពនៃការប្រមូលចំណូលពីវិស័យធនធានរ៉ែឱ្យអស់សក្តានុពល ជាពិសេស ផលិតផលរ៉ែនាំចេញក្រៅប្រទេស មានជាអាទិ៍៖ រ៉ែមាស រ៉ែដែកធៅ រ៉ែម៉ង់កាណែសធៅ រ៉ែខ្សាច់ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ ក្នុងនោះត្រូវចុះផ្ទាល់ដល់ការដ្ឋានអាជីវកម្មដោយក្រុមការងារអន្តរក្រសួង ស្ថាប័ន ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់សួយសារជាមួយបរិមាណធ្វើអាជីវកម្មជាក់ស្តែង,

• បន្តជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព រួមទាំងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង់ចំណូល ការកត់ត្រា និងការ-តាមដានការប្រមូលចំណូលមិនមែនសារពើពន្ធ,

• បន្តជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ច តាមរយៈការ-ប្រើប្រាស់ប្រព័ន្ធ NRMIS និងប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិក (e-Payment), ដោយចុះពិនិត្យផ្ទាល់ដល់ទីតាំង ឬការដ្ឋានអាជីវកម្ម ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រុមការងារអន្តរក្រសួង ស្ថាប័ន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ការបង់ចំណូល ព្រមទាំងពង្រឹងយន្តការប្រមូលចំណូល និងកិច្ចសហប្រតិបត្តិការរវាងក្រសួងជំនាញទទួលបន្ទុក,

• ជំរុញការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ជំនាន់ថ្មី ពេញលេញសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត,

• បន្តពិនិត្យ និងជំរុញក្រុមហ៊ុន ដែលទទួលបានសិទ្ធិពីរដ្ឋ សម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របណាមួយចំពោះករណីមិនមានអនុលោមភាព,

• ទប់ស្កាត់ការកកើតបំណុលមិនមែនសារពើពន្ធថ្មី និងបន្តចាត់វិធានការតឹងទារបំណុល ពិសេសពីវិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យអាកាសចរស៊ីវិល, ការជួលទ្រព្យសម្បត្តិរដ្ឋ,

• បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង។

## ៥.២- វិធានការផ្នែកចំណាយសម្រាប់ឆមាសទី ២ ឆ្នាំ ២០២៥

ផ្អែកតាមការវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងលទ្ធផលនៃការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធនៅឆមាសទី ១ និងដើម្បីធានាការអនុវត្តចំណាយថវិកាឱ្យមានប្រសិទ្ធភាព, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការផ្នែកចំណាយសម្រាប់ឆមាសទី ២ ដូចខាងក្រោម៖

• បង្កើនការពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពចំណាយរបស់ក្រសួង ស្ថាប័ន ដោយតម្រង់ទិសចាយឱ្យចំទិសដៅ តាមដែលអាចធ្វើទៅបានទាំងចំណាយចរន្ត និងគម្រោងវិនិយោគផ្ទាល់,

• បន្តពិនិត្យកែសម្រួលនីតិវិធីបន្ថែមតាមការចាំបាច់ ដោយមិនបោះបង់ចោលគោលដៅនៃការ-បង្កើនប្រសិទ្ធភាពចំណាយ និងការធានាបាន "តម្លៃនៃលុយ" ព្រមទាំងសមិទ្ធកម្មនៃកម្មវិធី ពោលគឺ មិនអនុញ្ញាតឱ្យចាយខ្ជះខ្ជាយ ដើម្បីឱ្យអស់ឥណទានថវិកាដែលមានក្នុងច្បាប់,

• ក្នុងខណៈដែលថវិកាគម្រោងវិនិយោគផ្ទាល់ និងថវិកាជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តកំពុងប្រឈមការលំបាក, គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបង្កើនការផ្តល់អាទិភាពលើការជួសជុល (Repair), កែលម្អ (Improve), និងលើកកម្រិត (Upgrade) សមិទ្ធផលដែលមានស្រាប់ ស្របតាមអតិក្រមពង្រឹងជាជាងពង្រីករបស់សម្តេចធិបតីនាយករដ្ឋមន្ត្រី,

- បន្តផ្សព្វផ្សាយជូនក្រសួង ស្ថាប័នអំពីក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមានសម្រាប់រៀបចំ និងអនុវត្តគម្រោងវិនិយោគផ្ទាល់ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ,
- បន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នឱ្យសិក្សាតម្លៃគម្រោងឱ្យបានច្បាស់លាស់ និងស្នើសុំធានាចំណាយគម្រោងដែលមានក្នុងផែនការឱ្យមានប្រសិទ្ធភាព និងទាន់ពេល,
- ជំរុញការអនុវត្តចំណាយទាំងផ្នែកចំណាយចរន្ត និងចំណាយវិនិយោគ ដោយថវិកាជាតិតាមរយៈការដាក់ជាវិធានការក្នុងការតាមដានវឌ្ឍនភាព ទាំងការអនុវត្តការងារជារូបវន្ត ការអនុវត្តនីតិវិធីលទ្ធកម្ម និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ដើម្បីធានាការទូទាត់ថវិកាស្របតាមកម្មវិធីចំណាយ និងជៀសវាងការទូទាត់កំហុគនៅចុងឆ្នាំ,
- ជំរុញក្រសួង ស្ថាប័នប្រគល់សិទ្ធិដល់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញក្នុងការបញ្ជាចំណូល និងប្រតិបត្តិការចំណាយ,
- បន្តពង្រឹងអង្គភាពថវិកានៃក្រសួង ស្ថាប័ន ទទួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្ម ឱ្យបានត្រឹមត្រូវ និងទាន់ពេល,
- បន្តជំរុញក្រសួង ស្ថាប័ន ក្នុងការកែលម្អចំណុចខ្វះចន្លោះនៅក្នុងដំណើរការគ្រប់គ្រង និងប្រតិបត្តិការរបស់ខ្លួន ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ អនុលោមភាព និងប្រសិទ្ធភាព តាមអនុសាសន៍ខាងសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ,
- បន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្ម និងលើកកម្ពស់ការចាត់វិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមានលើការអនុវត្តថវិកា,
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ស្របតាមផែនការ ជាពិសេសនៅតាមអង្គភាពថវិកាអាណាបកផ្ទេរសិទ្ធិពេញលេញ និងបន្តកិច្ចសហការរវាងអគ្គនាយកដ្ឋាន FMIS នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយនឹងក្រសួង ស្ថាប័ន ដើម្បីដោះស្រាយបញ្ហាទាំងក្នុងក្របខ័ណ្ឌរៀបចំនិងក្នុងពេលអនុវត្តប្រព័ន្ធ,
- បន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធនឹងការអនុវត្តថវិកា។

ជារួម, តាមរយៈការដាក់ចេញវិធានការចាំបាច់នានាខាងលើ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងខិតខំធានាឱ្យបានទាំងគោលដៅនៃការជំរុញល្បឿននៃការអនុវត្តចំណាយ ដោយផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃចំណាយ ទាំងលើទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពតម្លៃនៃលុយ ស្របតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន។

## ៦- សេចក្តីសន្និដ្ឋាន

ទោះបីផ្អែកតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ ២០២៥, សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើន **៥,០%** ប៉ុន្តែ ហានិភ័យពីកត្តាខាងក្រៅប្រទេស និងក្នុងប្រទេស តម្រូវឱ្យរាជរដ្ឋាភិបាលបន្តត្រៀម-លក្ខណៈឱ្យបានសមស្របក្នុងការបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ និងបញ្ហាប្រឈមនានា ដែលនឹងអាចកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញ និងការអនុវត្តវិធានការគោលនយោបាយឆ្លើយតបសមស្រប ទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ ជាក់ស្តែង, ស្ថានការណ៍ប្រែប្រួលក្នុងទិសដៅ

អវិជ្ជមានជាងការរំពឹងទុកពាក់ព័ន្ធនឹងការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ និងការដាក់អនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក បានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តចំណូលឆ្នាំ ២០២៥ ដែលតាមការប៉ាន់ស្មាន ចំណូលសរុបថវិការដ្ឋអាចនឹងសម្រេចបានប្រមាណ ៩៦,៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងខណៈដែលចំណាយមានតម្រូវការកាន់តែធំឡើង។

ដូចនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តតាមដានជាប្រចាំ ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងថវិកាឆ្នាំ ២០២៥ ជាថ្មីម្តងទៀត នៅខែ កញ្ញា ឆ្នាំ ២០២៥ ខាងមុខ។

ទោះបីការអនុវត្តថវិកាក្នុងឆមាសទី ១ កន្លងទៅនេះ នៅជួបប្រទះបញ្ហាប្រឈមមួយចំនួនក្តី ក៏ប៉ុន្តែដោយមានការគាំទ្រ និងការលើកទឹកចិត្តយ៉ាងពេញទំហឹង និងជាប្រចាំពី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលជាអគ្គមេបញ្ជាការតែមួយ នៃការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងស្មារតីនៃការបន្តចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្តេជ្ញាចិត្តដោយមិនរាថយក្នុងការពុះពារសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានលើកឡើងខាងលើ។

ដូចនេះ, ថវិកាឆ្នាំ ២០២៥ នៅតែជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងរក្សាលំនឹងជីវភាពប្រជាជន ក៏ដូចជាគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ឱ្យបានជោគជ័យ។ ជាមួយគ្នានេះ, ការអនុវត្តថវិកាឆ្នាំ ២០២៥ នឹងបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពប្រតិបត្តិការចំណាយ ដើម្បីធានាថា រាល់ចំណាយត្រូវធ្វើឡើងក្នុងថ្លៃសមរម្យ, មានគុណភាពខ្ពស់សមស្របតាមលទ្ធភាព ក្នុងបរិមាណដែលត្រូវការជាក់ស្តែង សម្រាប់ប្រើប្រាស់ក្នុងពេលដែលត្រូវការចាំបាច់; ព្រមទាំងការបន្តខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឹងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ដែលអាចឆ្លើយតបទៅនឹងតម្រូវការចំណាយ ស្របតាមប្រសិទ្ធនាមនៃថវិកាឆ្នាំ ២០២៥ គឺជា "ថវិកានៃការបោះជំហានទៅមុខយ៉ាងស្វាហាប់ ប្រកបដោយឆន្ទៈមោះមុតនិងការប្តូរប្តេជ្ញក្នុងការឆ្លងកាត់និងជម្នះ លើរាល់បញ្ហាប្រឈមនិងឧបសគ្គផងទាំងពួង ឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល ក្រោមម្លប់នៃសុខសន្តិភាព ដើម្បីជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយភាពធន់ បរិយាបន្ន និងមានចីរភាព ព្រមទាំងបែងចែកផលនៃកំណើននេះ ប្រកបដោយសមធម៌"។

***** ចប់ *****